# លន់ នល់ - សិរិមតៈ

## សត្រូវ ឬ មិត្ត ?



www.alamy.com - C4ACH6

សរសេរ ដោយ ឧប សៅ សង្ហា

គ្មានរក្សាសិទ្ធិ អ្នកនិពន្ធ

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

## មាតិការឿង


សេចក្ដីផ្ដើម ..... 4

សង្ខេប ជីវប្រវត្តិ របស់លោក លន់ នល់ ..... 8

សង្ខេប ជីវប្រវត្តិ របស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ..... 13

រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ..... 16

ហេតុអ្វី បាន ជា លោក លន់ នល់ ត្រូវការ ទ្រង់ សិរិមតៈ ? ..... 19

ទំនាស់ សម្ដេច សីហនុ នឹង រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ..... 20

សកម្មភាព នៃ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ..... 24

ជំហរ នៃ រដ្ឋសភា ..... 26

សមាជជាតិ ចុងក្រោយ ..... 29

ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០ ..... 32

គោលជំហរ របស់ទ្រង់ សិរិមតៈ ..... 33

ហេតុអ្វី បាន ជា ទ្រង់ សិរិមតៈ ជា សត្រូវ នឹង សីហនុ ? ..... 35

ក្នុង វិស័យ រាជានិយម ..... 36

ក្នុង វិស័យ នយោបាយជាតិ ..... 38

ក្នុង វិស័យ នយោបាយអន្តរជាតិ ..... 40

គោលជំហរ របស់លោក លន់ នល់ ..... 41

ការបដិសេធ របស់សម្ដេច សីហនុ ទទួលស្ដាប់ ប្រតិភូ របស់ព្រះមហាក្សត្រីយានី ..... 42

កត្តាកងទ័ព ..... 44

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ចិត្តពង្វាង ឬ ប្រើកល់ របស់សម្តេច សីហនុ ... 46
កត្តា នៃ លោកសេរី ... 50
កត្តាកំណត់រួម របស់លោក លន់ នល់ និង ទ្រង់ សិរិមតៈ ... 51
អ្នករាជានិយម ... 51
អ្នកជាតិនិយម ... 52
អ្នកប្រជាធិបតីសេរី ... 52
កត្តា នៃ គំនិតអសទិស រវាង លោក លន់ នល់ នឹង ទ្រង់ សិរិមតៈ ... 53
ចប់ ... 59

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

## សេចក្តីផ្តើម

លោក លន់ នល់ និង អ្នកអង្គម្ចាស់[1] ស៊ីសុវត្ថិ សិរិមតៈ ជា មនុស្ស ជំនាន់ តែមួយ។ ទ្រង់ សិរិមតៈ កើត នៅថ្ងៃ ទី២២ មក

---

[1] នៅក្នុង ព្រះរាជវង្សានុវង្ស មាន លំដាប់ជួរងារ របស់ ស្តេច (ពាក្យ ប្រើ ជា ទូទៅ សំរាប់ សមាជិក ព្រះរាជវង្សានុវង្ស - prince et princesse) : ជួរងារទី១ គឺ ព្រះអង្គម្ចាស់ក្សត្រា និង ព្រះអង្គម្ចាស់ក្សត្រី ដែល ជា ព្រះរាជបុត្រា ឬ បុត្រី របស់ ព្រះមហាក្សត្រ ឬ ស្តេច គ្រងរាជ្យ ឬ ហ្លួង, ជួរងារទី២ គឺ អ្នកអង្គម្ចាស់ក្សត្រា និង អ្នកអង្គម្ចាស់ក្សត្រី ដែល ជា ព្រះរាជនត្តា (ចៅ ប្រុស ស្រី) របស់ ព្រះមហាក្សត្រ, ជួរងារទី៣ គឺ អ្នកអង្គរាជវង្សក្សត្រា និង អ្នកអង្គរាវង្សក្សត្រី គឺ ជា ចៅលួត របស់ ព្រះមហាក្សត្រ ។ នៅជំនាន់ អាណាព្យាបាល បារាំងសែស, នៅក្នុង ពិធីការ ជាផ្លូវការ បារាំង គេ ប្រដូច ព្រះអង្គម្ចាស់ក្សត្រា ឬ ព្រះអង្គម្ចាស់ក្សត្រី ទៅនឹង « Duc, Duchesse », អ្នកអង្គម្ចាស់ក្សត្រា ឬ អ្នកអង្គម្ចាស់ក្សត្រី ទៅនឹង « Comte, Comtesse » រីឯ អ្នកអង្គរាជវង្សក្សត្រា ឬ អ្នករាជវង្សក្សត្រី ទៅនឹង « Vicomte, Vicomtesse »។ ស្តេចក្សត្រី ពាក់ងារអ្វីក៏ដោយ បើ មាន ស្វាមី ជា រាស្ត្រ បើ មាន បុត្រា គេឱ្យងារ ជា កែវ រីឯ បុត្រី វិញ គេឱ្យងារ ជា យុន។ ពាក្យ យុន ក៏ប្រើ សំរាប់ ងារ មហេសី របស់ ស្តេច គ្រងរាជ្យ ឬ ក៏ ជា ភរិយា របស់ មហាមន្ត្រីធំៗ, ដូច្នេះឯង បាន ជា ពាក្យ កែវ គេ ប្រើ ជា ទូទៅ សំរាប់ ហៅ បុត្រា ឬ បុត្រី ដែល មាន បិតា ជា រាស្ត្រ។ ស្ត្រី ជា រាស្ត្រ មាន ស្វាមី ជា ស្តេច មាន ងារ ជាអ្វីក៏ដោយ គេឱ្យងារ ជា អ្នកម្នាង។ អ្នកម្នាង មិនអាច ពាក់ ងារ ជា ព្រះអង្គម្ចាស់ក្សត្រី, អ្នកអង្គម្ចាស់ក្សត្រី និង អ្នកអង្គរាជវង្សក្សត្រី បាន ជា ដាច់ខាត ក៏ដូចគ្នានឹង បុត្រា បុត្រី របស់ ស្តេចក្សត្រី ដែល មាន ស្វាមី ជា រាស្ត្រ នោះដែរ។ តែបើ ស្ត្រី ជា រាស្ត្រ ត្រូវ បាន ព្រះមហាក្សត្រ លើកតម្កើត ជា ព្រះអគ្គមហេសី, ស្ត្រីនោះ ក្លាយ ជា ស្តេចក្សត្រី ពេញសិទ្ធិ គឺថា ត្រូវប្រើ រាជវាក្យសព្ទ ចំពោះព្រះអង្គ ដែល អ្នកម្នាង ពុំបាន ទទួល បុព្វសិទ្ធិនេះឡើយ ព្រោះ ខ្លួន ស្ថិតនៅ ជា រាស្ត្រ។ ត្រូវដឹងថា នៅថ្ងៃ ទី១ មករា ឆ្នាំ ១៩០៧ ទើប មាន រាជបញ្ញាតិ អនុញ្ញាត ឱ្យ ស្តេចស្រី មាន សិទ្ធិ រៀបអាពាហ៍ពិពាហ៍ ជាមួយ បុរស ជា រាស្ត្រ, ហើយ កូន ដែល កើត ពី សម្ពង្សនេះ ត្រូវ យក នាមត្រកូល ឪពុក ជា នាមត្រកូល របស់ខ្លួន ហើយ គ្មានងារ ជា ស្តេច នោះឡើយ, រីឯ ស្តេចស្រី ជា ភរិយា ជា មាតា នោះ អាចរក្សា ងារ ជា ស្តេចបាន។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

រា ឆ្នាំ ១៩១៤ នៅ ភ្នំពេញ, រីឯ លោក លន់ នល់ កើត នៅថ្ងៃ ទី ១៣ វិច្ឆិកា ឆ្នាំ ១៩១៣ នៅ ស្រុក កំពង់លើ ក្នុង ខេត្ត ព្រៃវែង។ លោក កើត នៅក្នុង វង្សត្រកូល មន្ត្រី ជា អ្នកបំរើ រាជការ (ជីតា របស់លោក ធ្លាប់ធ្វើ ចៅហ្វាស្រុក នៅ ខេត្ត សៀមរាប និង កំពុងធំ, ហើយ ជីតាទួត ធ្លាប់ធ្វើ ចៅហ្វាយ ខេត្ត កំពង់ធំ) រីឯ ទ្រង់ សិរិមតៈ ជា បុត្រា របស់ ស្ដេច ជាមួយ ស្រ្ដី ជា រាស្ដ្រ។ ព្រះអង្គ ជា ចៅ របស់ ហ្លួង ស៊ីសុវត្ថិ។

លោក លន់ នល់ និង ទ្រង់ សិរិមតៈ មាន វាសនារួម នៅក្នុង ការជំទាស់ នយោបាយ នឹង សម្ដេច សីហនុ។ ដើមឡើយ ជា ទំនាស់ ក្នុង វិស័យ នយោបាយ សេដ្ឋកិច្ច នាំរីកសាយ ចូលទៅ ក្នុង វិស័យ មនោគមវិជ្ជា ដែល នាំបង្កើត សង្គ្រាម នៅស្រុកខ្មែរ រវាង យួនយៀកកុង នឹង សាធារណរដ្ឋខ្មែរ ព្រោះ សម្ដេច សីហនុ ទ្រង់ ធ្វើការអំពាវនាវ ឱ្យទ័ពយួនយៀកកុង វាយប្រហារ កង ទ័ពជាតិខ្មែរ ដើម្បី ដណ្ដើម អំណាច យកមកវិញ ដែល ព្រះអង្គ បាត់បង់ ព្រោះ សភាជាតិ បានបោះឆ្នោត ទំលាក់ ព្រះអង្គ ពី តំណែង ព្រះប្រមុខរដ្ឋ នៃ ព្រះរាជាណាចក្រ កម្ពុជា នៅថ្ងៃ ទី ១៨ មីនា ឆ្នាំ ១៩៧០។ សួរថា តើ ទំនាក់ទំនង លោក លន់ នល់ នឹង ទ្រង់ សិរិមតៈ វា មាន ធម្មជាតិ បែបណា ដែល នាំ អ្នក ទាំងពីរ មាន សេចក្ដីក្លាហាន ហ៊ាន រួមគ្នា បំពានវាំង ដើម្បី រំលំ

---

សព្វថ្ងៃ នៅក្នុង ព្រះរាជវង្សានុវង្ស គ្មានមាន ការគោរព រាជប្រពៃណី ច្បាស់លាស់នោះឡើយ, សួរ ថា មកពី មិនដឹង ? ឬ ក៏ ព្រះមហាក្សត្រខ្មែរ ព្រះអង្គ ប្រទាន ងារ ដោយ បំពាន លើ រាជប្រពៃណី សហស្សវត្ស ?

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

របប សង្គមរាស្ត្រនិយម ដែល នៅពេលនោះ ប្រជារាស្ត្រខ្មែរ ទុក ជា ទេពសសរស្តម្ភ ទ្រទ្រង់ ព្រះរាជាណាចក្រខ្មែរ ដែល មាន ស ម្តេច សីហនុ ជា អាទិទេព រក្សា រាជនគរ ? ទ្រង់ សិរិមតៈ ជា ស្តេ ច រីឯ លោក លន់ នល់ ជា រាស្ត្រ, ចុះហេតុអ្វី ក៏បាន ជា ស្តេច ចូលរួម បង្កើត របប សាធារណរដ្ឋ ជាមួយ រាស្ត្រ ដែល ជា របប ប្រឆាំងនឹង របប រាជានិយម តាម គោលការណ៍ នៃ មនោគម វិជ្ជា ? លោក លន់ នល់ ជា អ្នកបំរើ ដ៏ស្មោះម្នាក់ ហើយ ជា ទី ស្រឡាញ់ បំផុត របស់ សម្តេច សីហនុ, ចុះហេតុអ្វី បែរ ជា លោក ហ៊ាន ក្បត់ មក ជ្រើសរើស យក ទ្រង់ សិរិមតៈ ជា ដៃគូ ក្នុង អំពើក្បត់ របស់គាត់ ? តែ សួរថា តើ ពិត ជា អំពើ ក្បត់ ឬ ជា កម្មវិបាក នៃ នយោបាយ មិនអាចយល់បាន របស់ សម្តេច សីហនុ ដែល នាំឱ្យ លោក លន់ នល់ ធ្វើជម្រើស បែបនោះ ? យើងឃើញថា វាមានសំនួរ ច្រើនជាអសង្ខយ្យ[2] ដែលនៅក្នុង សៀវភៅនេះ យើង សាកល្បង នឹងបំភ្លឺ តាម ការចេះដឹង មាន កំរិត របស់យើង អំពី ហេតុផល ដែល នាំឱ្យ លោក លន់ នល់ និង ទ្រង់ សិរិមតៈ រួបរួមគ្នាបាន នៅចំពោះមុខ អំណាច ហួស ហេតុ របស់ សម្តេច សីហនុ។

ត្រូវដឹងថា ប្រជានុរាស្ត្រខ្មែរ ជា ប្រជានុរាស្ត្ររាជានិយម សហស្ស វត្ស ទុក ព្រះមហាក្សត្រ ជា បិតាជាតិ និង បិតា របស់ខ្លួនផ្ទាល់។ ទោះបី សម្តេច សីហនុ ព្រះអង្គ បានដាក់ រាជ្យសម្បត្តិ ដើម្បី

2 អសង្ខេយ្យ: ដែលច្រើនរាប់ពុំអស់, ដែលរាប់ពុំបានប្រមាណពុំអស់។

ថ្វាយ ព្រះរាជបិតា របស់ព្រះអង្គ, នរោត្តម សុរាម្រិត (១៨៨៦-១៩៦០)[3], តែ បន្ទាប់ ពី បិតា ព្រះអង្គ ចូលទិវង្គត ទ្រង់ ពុំព្រម ឡើងគ្រងរាជ្យ បន្ត ហើយ ទុក ស្ថាប័ន ព្រះមហាក្សត្រ នៅ ទំនេរ ដោយ គ្រាន់តែ តែងតាំង ព្រះមាតា ជា តំណាង ស្ថាប័ន, តែ ប្រជារាស្ត្រខ្មែរ ភាគច្រើន ដាច់ខាត នៅតែ ទុក សម្តេច សីហនុ ជា មហាក្សត្រ ដដែល។ ដូច្នេះ ទំនាស់ នឹង សម្តេច សីហនុ វា អាច ទុក ជា ទំនាស់ នឹង ព្រះមហាក្សត្រ តែម្តង នៅក្នុង ស្មារតី របស់ ប្រជារាស្ត្រខ្មែរ។ បន្ថែមពីលើនេះទៀត សម្តេច សីហនុ ព្រះ អង្គ មាន មុខងារ ជា ព្រះប្រមុខរដ្ឋ អស់មួយជីវិត, នៅក្នុង មុខងារនោះឯង ដែល ព្រះអង្គ ថ្លែង ជំទាស់ នឹង រដ្ឋសភា ដែល បោះឆ្នោត ទំលាក់ ព្រះអង្គ ពីតំណែង អស់មួយជីវិត ថា ជា រដ្ឋ ប្រហារ ព្រោះ ជា ទង្វើ មិនស្របច្បាប់[4]។ តែ គួរយល់ឃើញដែរថា

---

[3] នរោត្តម សុរាម្រិត (១៨៨៦-១៩៦០) ឡើង គ្រងរាជ្យ នៅថ្ងៃ ទី ៥ មីនា ឆ្នាំ ១៩៥៥, ចូលទិវង្គត នៅថ្ងៃ ទី៣ មីនា ឆ្នាំ ១៩៦០ ក្នុង ជន្មាយុ ៧៤ ឆ្នាំ, ហើយនៅពេល ព្រះបិតា ព្រះអង្គ ចូលទិវង្គត។

[4] **គោលជំហរ របស់រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ :**
(ដកស្រង ពី សេចក្តីប្រកាស របស់ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ចុះ ថ្ងៃទី ៥ មេសា ឆ្នាំ ១៩៧០)នៅ ឆ្នាំ ១៩៦០ បន្ទាប់ ពី ប្រជាបាតុកម្ម ស ម្តេច សីហនុ ត្រូវ បាន ប្រកាស ជា ប្រមុខរដ្ឋ អស់មួយ ជីវិត ដោយ ប្រធាន រដ្ឋសភា នៅ ក្នុង អង្គប្រជុំ ជា សាធារណៈ ដោយ គ្មាន ការបោះ ឆ្នោត ជា មុន។ ក្រោយ ពី ការប្រកាស នេះ មក គឺ គ្រាន់ តែ មាន ការ ទះដៃ ពីសំណាក់ តំណាងរាស្ត្រ ដើម្បី អនុម័ត ការប្រកាស នោះ តែ ប៉ុណ្ណោះ។ ផ្ទុយទៅវិញ នៅ ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០, បន្ទាប់ ពី ប្រជា បាតុកម្ម ប្រឆាំងនឹង សីហនុ, សភាជាតិ បាន ប្រកាស ដកដំណែង ប្រមុខរដ្ឋ អស់មួយ ជីវិត ពី សម្តេច សីហនុ តាម ការបោះឆ្នោត ជា សា ធារណៈ នៅ លើវេទិកា (s’est prononcé au scrutin public à la tribune) : ៩២ សម្លេង ចេញ ពី ៩២ មាន វត្តមាន។ ដោយ អាស្រ័យ ក្បួន ស្រប និយម នៃ ទម្រង់ (règle du parallélisme des formes), អ្វី ដែល សភា

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០ ជា ទំនាស់ ជា ប្រវត្តិសាស្ត្រ រវាង រាជសក្តិ[5] ពាន់ឆ្នាំ ដែល មាន សម្តេច សីហនុ ជា អវតា នឹង អំណាចតំណាង វ័យក្មេង ដែល មាន រដ្ឋសភា និង រដ្ឋាភិបាល បន្ទាប់មក មាន របប សាធារណរដ្ឋ ជា អវតា។ ជម្លោះនោះ វា មាន រូបភាព ជា បដិឃោគ ផងដែរ រវាង « គំនិតចាស់ និង គំនិតថ្មី » នៅក្នុង សង្គម បុរាណ និង និច្ចលភាព ដែល ថាស នៃ គំនិតចាស់ នៃ ជញ្ជីង វា ច្បាស់ ជា ធ្ងន់ជាង ថាស នៃ គំនិតថ្មី។ វា នឹងអាច ជា ការមិនពិត ក៏ វា នឹងអាច ជា ការពិត ដែល យើង នឹងលើក មកបកស្រាយ នៅពេលខាងមុខនេះ។

### សង្ខេប ជីវប្រវត្តិ របស់លោក លន់ នល់

បន្ទាប់ ពីបាន សិក្សា នៅ វិទ្យាល័យ Chasseloup-Laubat នៅ ទីក្រុង សាយហ្គន (ព្រៃនគរ) ពី ឆ្នាំ ១៩២៨ ដល់ ១៩៣៤។ បន្ទាប់មក លោក ប្រឡងចូល សាលា រដ្ឋបាល[6] ហើយ សិក្សា

ជាតិ នៅ ពេល នុះ បាន បង្កើត ឲមាន, សភាជាតិ មួយទៀត ក៏ អាច លុប វិញ បាន នោះដែរ។ ដូច្នេះ បើ រដ្ឋសភា នៅ ឆ្នាំ ១៩៦០ បាន តែងតាំង សម្តេច សីហនុ ជា ប្រមុខរដ្ឋ, សភាជាតិ នៅ ឆ្នាំ ១៩៧០ ក៏ អាច ដកហូត តំណែង ព្រះអង្គ បាន ដែរ នៅក្នុង ទម្រង់ ច្បាប់ ដូច គ្នា។ ដូច្នេះ វា គ្មាន ចាំបាច់ មាន បទប្បញ្ញតិ យ៉ាង ច្បាស់ ណា មួយ សំរាប់ ទំលាក់ ប្រមុខរដ្ឋ នោះឡើយ។ ម្យ៉ាងមួយទៀត សម្តេច សីហនុ ទាមទារ ថា តំណែង របស់ ព្រះអង្គ ជា តំណែង អស់មួយ ជីវិត។ ជា ធម្មតា នៅក្នុង រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ គេ ឃើញ មាន តែ ព្រះមហាក្សត្រ ម្នាក់ គត់ ដែល ទទួល តំណែង អស់មួយ ជីវិត។

[5] រាជសក្តិ : រាជអំណាច។

[6] ដើមឡើយ មានឈ្មោះ ថា « សាលា ក្រមការ » ដែល បារាំង គេ បង្កើត នៅ ស្រុកខ្មែរ នៅឆ្នាំ ១៩១៧ ដើម្បី បង្ហាត់បង្រៀន បុគ្គលិក លេខាធិការ រដ្ឋបាល (ឃោក្ស័ត) និង ក្រឡាបញ្ជី តុលាការ។ អ្នក ដែល

អស់ រយៈពេល ពីរឆ្នាំ ក្នុង ផ្នែក តុលាការ។ ក្រោយពី បញ្ចប់ សិក្សា លោក ត្រូវបាន តែងតាំង ជា ចៅក្រម នៅ តុលាការ នៃ ខេត្ត សៀមរាប។ នៅឆ្នាំ ១៩៣៧ លោក សុំប្តូរ មុខងារ ជា ចៅក្រម មកជា មន្ត្រី រដ្ឋបាល នៅ ខេត្ត កំពង់ចាម។ នៅឆ្នាំ

---

អាច ប្រឡងប្រជែង ចូលសិក្សាបាន ត្រូវមាន «វិញ្ញាបនប័ត្រ បឋមសិក្សា»។ រយៈពេលសិក្សា ២ឆ្នាំ, កម្មវិធី សិក្សា ជា ភាសាខ្មែរ តែ សិស្សានុសិស្ស ត្រូវចេះអាន និង សរសេរ ភាសា បារាំង ក្នុង កំពស់ទាបមួយ ដើម្បី អាច អាន និង ចម្លង ឯកសារ ជា អក្សរបារាំង។ ក្រោយមកទៀត បារាំង គេ បង្កើត «ផ្នែក អនុមន្ត្រី» ហើយ អ្នក ដែល អាច ប្រឡងប្រជែង ចូលសិក្សាបាន ត្រូវ មាន «សញ្ញាប័ត្រ មធ្យមសិក្សា»។ ផ្នែកនេះ គឺ សំរាប់ បង្ហាត់បង្រៀន អនុមន្រ្តី រដ្ឋបាល និង តុលាការ (ភូឈួយចៅក្រម)។ រយៈពេលសិក្សា ២ឆ្នាំ, កម្មវិធី សិក្សា ជា ភាសាបារាំង។ ក្រោយមកទៀត នៅ សម័យ ស្រុកខ្មែរ ឯករាជ្យ បារាំង គេ បង្កើត ផ្នែក «វរៈមន្ត្រី» ហើយ អ្នក ដែល អាច ប្រឡងប្រជែង ចូលរៀនបាន ត្រូវមាន បរិញ្ញាបត្រ ច្បាប់ ឬ សេដ្ឋកិច្ច ឬ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រ ឬ អនុមន្ត្រី ដែល មាន សញ្ញាប័ត្រ ផ្នែក អនុមន្ត្រី ហើយ បំរើ រាជការ ក្នុង រយៈពេល មាន កំរិតមួយរយៈ។ ផ្នែក វរៈនេះ គឺ សំរាប់ បង្ហាត់បង្រៀន វរៈមន្ត្រី រដ្ឋបាល, ទូត និង ចៅក្រម។ បារាំង គេ បិទ ផ្នែក យោក្សប័ត្រ និង ក្រឡាបញ្ជី តុលាការ ហើយ ដូរ ឈ្មោះ «សាលាភូមិន្ទ រដ្ឋបាល»។ សាលានោះ ត្រូវបាន សម្តេច សីហនុ បិទទ្វារ នៅ ទស្សវត្ស ៦០ បន្ទាប់ ពី មាន កើត ជម្លោះមួយ រវាង សិស្សានុសិស្ស ជាមួយនឹង នាយកដ្ឋាន សាលា ស្តីពី តម្រូវឱ្យ សិស្សានុសិស្ស ពាក់ ឯកសណ្ឋាន។ នៅ ជំនាន់ សាធារណរដ្ឋខ្មែរ សាលានេះ បានបើកទ្វារឡើងវិញ ដូរ ឈ្មោះ «សាលាជាតិ រដ្ឋបាល»។ ត្រូវដឹងថា សិស្សានុសិស្ស ដែល ចូលប្រឡងប្រជែង ចូល ផ្នែក អនុមន្ត្រី ច្រើន តែ សិស្សានុសិស្ស ថ្នាក់ទី១ នៃ វិទ្យាល័យ ទើបអាចមាន សង្ឃឹមច្រើន នឹងអាច ប្រឡងជាប់ ព្រោះ មាន កំរិត ចំនួន សិស្ស នៅ ជំនាន់ និមួយៗ, ដូច្នេះ មាន ការប្រកួតប្រជែង គ្នា ខ្លាំងណាស់ ដើម្បី កៅអី សាលា។ ដូច ករណី លោក លន់ នល់ និង ទ្រង់ សិរិមតៈ។ សាលានេះ នៅក្រោម ការត្រួតត្រា របស់ បារាំង រហូត ដល់ សម្តេច សីហនុ បិទទ្វារ សាលា។ ដូច្នេះ អ្នក ដែល មាន សញ្ញាប័ត្រ ថ្នាក់ វរៈមន្ត្រី, មហាវិទ្យាល័យ មួយចំនួន នៅ ស្រុកបារាំង គេ ផ្តល់ លទ្ធភាព ឱ្យធ្វើ និក្ខេបបទ ថ្នាក់ បណ្ឌិត ជំនាញ ក្នុង វិស័យ ច្បាប់ រដ្ឋបាល និង បណ្ឌិត មហាវិទ្យាល័យ បាន។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

១៩៤៥ ថ្ងៃ ទី៩ ខែ មីនា កងទ័ព ជប៉ុន បាន រំលាយ អាណាព្យាបាល អាណានិគម(?)

១៩៤៥ ថ្ងៃ ទី៩ ខែ មីនា កងទ័ព ជប៉ុន បាន រំលាយ អាជ្ញាធរ បារាំង នៅ ឥណ្ឌូចិន ដោយ ចាប់ ជនជាតិបារាំង ទាំងអស់ ដាក់ ពន្ធនាគារ ហើយ នៅ ស្រុកខ្មែរ អាជ្ញាធរ ជប៉ុន ស្នើឱ្យ ហ្លួង សីហនុ ប្រកាស ឯករាជ្យ នៅថ្ងៃ ទី១២ មីនា, នៅខែ ឧសភា លោក លន់ នល់ ត្រូវបាន រាជការខ្មែរ តែងតាំង ជា ចៅហ្វាសយ ខេត្ត ក្រចេះ បន្ទាប់មក ជា អគ្គស្នងការ នៃ នគរបាលជាតិ។ បន្ទាប់ ពីចប់ សង្គ្រាម លោក លើកទី២, ជប៉ុន ចាញ់ សង្គ្រាម ហើយ បារាំង វិលត្រឡប់មកត្រួតត្រា ស្រុកខ្មែរវិញ, នៅឆ្នាំ ១៩៤៦ លោក លន់ នល់ ត្រូវបាន រាជរដ្ឋាភិបាលខ្មែរ តែងតាំង ជា អ្នកដឹកនាំ គណប្រតិភូខ្មែរ ចូលរួម ជាមួយ អាជ្ញាធរ បារាំង ចរចា នឹង រាជរដ្ឋាភិបាលថៃ ដើម្បី ឱ្យគេ ប្រគល់ ខេត្ត បាត់ដំបង មកឱ្យខ្មែរវិញ។ បន្ទាប់ ពី សៀម ប្រគល់ ខេត្ត បាត់ដំបង លោក លន់ នល់ បន្ត បេសកកម្ម រៀបចំ រដ្ឋបាលខេត្តនេះ ឡើងវិញ ហើយ បន្ទាប់មក ត្រូវ តែងតាំង ជា អភិបាល ខេត្ត នៅឆ្នាំ ១៩៤៧។ មកដល់ ឆ្នាំ ១៩៥១ លោក ជា ប្រធាន គណបក្ស នយោបាយ ឈ្មោះ « ខេមរ ប៉ុន្នការ » ដើម្បី ចូលរួម បោះឆ្នោត ជ្រើសរើស តំណាងរាស្ត្រ, ប៉ុន្តែ មិនបាន ទទួល អាសនៈ នៅក្នុង សភាជាតិ នោះឡើយ។ នៅឆ្នាំ ១៩៥២ ហ្លួង សីហនុ បានតែងតាំង លោក លន់ នល់ ជា មេបញ្ជាការ ប្រតិបត្តិការសឹក នៅ ខេត្ត បាត់ដំបង, មានឋានន្តរស័ក្តិ ជា វរសេនីយទោ នៃ កងទ័ព ជើងគោក, ប្រឆាំង នឹង យួនវៀតមិញ និង ចលនា ខ្មែរឥស្សរៈ របស់លោក សឹង

# លន់ នល់ - ជីវិតៈ : សត្រូវ ឬ មិត្ត ?

ដុំកថាញ់។ បន្ទាប់ ពី សន្និសិទ្ធ ទីក្រុង ហ្សឺណែវ នៅឆ្នាំ ១៩៥៤, លោក លន់ នល់ ត្រូវបាន តែងតាំង ជា ប្រធាន គណកម្មការ ចំរុះ បង្កើតឡើង នៅក្នុង ក្របខណ្ឌ នៃ សន្និសិទ្ធនោះ ដើម្បី ពិនិត្រ ការដកទ័ព របស់ យួនវៀតមិញ ចេញពី កម្ពុជា។ មក ដល់ឆ្នាំ ១៩៥៥ លោក លន់ នល់ ត្រូវបាន តម្លើង ឋានន្តរស័ក្តិ ជា ឧត្តមសេនីយ ហើយ ត្រូវបាន ហ្លួង សីហនុ តែងតាំង ជា អគ្គនាយសេនាធិការ នៃ កងទ័ព ខេមរភូមិន្ទ។ នៅឆ្នាំ ១៩៥៩, លោក លន់ នល់ ត្រូវបាន តែងតាំង ជា អគ្គមេបញ្ជាការ នៃ កងទ័ពខេមរភូមិន្ទ និង ជា រដ្ឋមន្ត្រី ក្រសួង ការពារជាតិ ដែល មាន សម្តេច ជា នាយករដ្ឋមន្ត្រី ហើយ លោក រក្សា តំណែង រដ្ឋ មន្ត្រី នៅក្នុង គណរដ្ឋមន្ត្រី បន្តបន្ទាប់មក។ មកដល់ឆ្នាំ ១៩៦៦ ត្រូវបាន សភាជាតិ ជ្រើសរើសលោក ជា នាយករដ្ឋមន្ត្រី។ ក្រោយពី មានគ្រោះថ្នាក់ រថយន្ត, លោក បានលាលែងពី តំណែង នៅឆ្នាំ ១៩៦៧។ ពីឆ្នាំ ១៩៦៨ ដល់ ១៩៦៩ លោក ត្រូវ បាន តែងតាំង ជា ឧបនាយករដ្ឋមន្ត្រី ទី៣ បន្ទាប់មក ទី១ នៅក្នុង រដ្ឋាភិបាល ដឹកនាំដោយ សម្តេច ប៉ែន នុត ហើយ បន្ទាប់មក ត្រូវបាន សភាជាតិ តែងតាំង ជាថ្មី ជា នាយករដ្ឋ មន្ត្រី។ នៅថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០, រដ្ឋសភា បានបោះឆ្នោត ទម្លាក់ សម្តេច សីហនុ ពីមុខដំណែង ប្រមុខរដ្ឋ នៅពេលទ្រង់ កំពុង ធ្វើ រាជទស្សនាកិច្ច ជា ឯកជននៅ ប្រទេសបារាំង, ដូច្នេះ លោក ចេង ហេង ជា ប្រធានរដ្ឋសភា បានក្លាយ ជា ប្រមុខរដ្ឋ ជំនួស ព្រះអង្គ។ សង្គ្រាម បានផ្ទុះឡើង ដែល មាន

## លន់ នល់ - ជីវិតៈ : សត្រូវ ឬ មិត្ត ?

កងទ័ពយៀកកុង និង រណសិរ្ស បង្រួបបង្រួមជាតិខ្មែរ ដឹកនាំ ដោយ សម្ដេច សីហនុ ពី ទីក្រុង ប៉េកាំង ជា អ្នកវាយប្រហារ កងទ័ពជាតិខ្មែរ ដោយ គ្មានប្រកាស ជាមុន។ សាធារណរដ្ឋខ្មែរ បានត្រូវប្រកាសឡើង នៅថ្ងៃ ទី៩ តុលា ឆ្នាំ ១៩៧០។ រដ្ឋសភាជាតិ បានក្លាយទៅជា រដ្ឋសភា ធម្មនុញ្ញ ដើម្បី តាក់តែ រដ្ឋធម្មនុញ្ញថ្មី, ប៉ុន្តែ នៅថ្ងៃ ទី១២ មីនា ឆ្នាំ ១៩៧២, លោក លន់ នល់ បានប្រកាស តាំង ខ្លួនលោក ជា ប្រធានាធិបតី បន្ទាប់ ពី លោក ចេង ហេង បាន លាលែង ពី តំណែង ប្រមុខរដ្ឋ។ នៅថ្ងៃ ទី៣០ មេសា ឆ្នាំ ១៩៧២ រដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋខ្មែរ ត្រូវបានអនុម័ត, បន្ទាប់មកនៅថ្ងៃ ទី៤ មិថុនា ឆ្នាំ១៩៧២, លោក លន់ នល់ បានជាប់ឆ្នោត ជា ប្រធានាធិបតី។ លោក ដឹកនាំនយោបាយ និង សង្គ្រាម ការពារ បូរណភាពទឹកដីខ្មែរ រហូតដល់ ថ្ងៃ ទី ១ មេសា ឆ្នាំ ១៩៧៥, ថ្ងៃ ដែល លោក ចាកចេញ ពី ស្រុកខ្មែរ ដើម្បី បើកទ្វារចំហរ ឱ្យមាន ការចរចា រវាង ភាគីខ្មែរ សាធារណរដ្ឋខ្មែរ នឹង រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិខ្មែរ ដឹកនាំដោយ សម្ដេច សីហនុ ដើម្បី បញ្ចប់ សង្គ្រាម រវាង ខ្មែរ នឹង ខ្មែរ។ លោក បានទទួលអនិច្ចកម្ម នៅថ្ងៃ ទី១៧ វិច្ឆិកា ឆ្នាំ ១៩៨៥ ក្នុង ជន្មាយុ ៧២ ឆ្នាំនៅ រដ្ឋកាលីហ្វ័រនី នៅ សហរដ្ឋអាមេរិក។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

## សង្ខេប ជីវប្រវត្តិ របស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ

ស្តេច សិរិមតៈ ទ្រង់ សិក្សា នៅ វិទ្យាល័យ Chasseloup-Laubat នៅ ទីក្រុង សាយហ្គន (ព្រៃនគរ)។ ទ្រង់ បានចូល បំរើ រាជការ ក្នុង នាយកដ្ឋាន រដ្ឋបាល ផ្សេងៗ។ បន្ទាប់មក ត្រូវបាន ហ្លួង សីហនុ ប្រគល់ បេសកកម្ម ធ្វើការចរចា ជាមួយ ក្រុម ខ្មែរឥស្សរៈ ហើយ ជោគជ័យ ដ៏ ធំមួយ របស់ ទ្រង់ គឺ ការចរចា ជាមួយ ដាប ឈួន, មេ ខ្មែរឥស្សរៈ ដ៏សំខាន់ម្នាក់, ដែល នរៈនេះ សុខចិត្ត ដាក់អាវុធ ចុះចូល រាជរដ្ឋាភិបាល នៅឆ្នាំ ១៩៤៩។ វិធីបុណ្យអធិកអធមមួយ បានរៀបចំឡើង ដោយ រាជរដ្ឋាភិបាល នៅ អង្គរធំ ទទួល ដាប ឈួន និង ក្រុមគាត់ ចំនួន ៤00 នាក់ ចូលខ្លួន ថ្វាយអាវុធ ដល់ ហ្លួង សីហនុ។ នៅពេល ព្រះបូជនីយកិច្ច, ទ្រង់ សិរិមតៈ ចូលខ្លួន បំរើកងទ័ព ជា វរសេនីយឯក នៃ កងទ័ព ជើងគោក។ ទ្រង់ ធ្លាប់ កាន់តំណែង ជា អគ្គនាយសេនា នៃ កងទ័ពខេមរៈភូមិន្ទ។ ក្រោយមកទៀត ទ្រង់ បាន ត្រូវតែងតាំង ច្រើនដង ជា សមាជិក នៃ រាជរដ្ឋាភិបាល : នៅ ឆ្នាំ ១៩៥២ ជា ទេសរដ្ឋមន្ត្រី ក្រសួងការពារជាតិ, ប៉ុស្ត៍ និង ទូរគមនាគមន៍ ដែល មាន ហ្លួង សីហនុ ជា នាយករដ្ឋមន្ត្រី, នៅ ឆ្នាំ ១៩៥៣ នៅក្នុង គណរដ្ឋមន្ត្រី ដឹកនាំដោយ លោក ប៉ែន នុត ជា រដ្ឋមន្ត្រី ក្រសួង ការបរទេស បន្ទាប់មក ជា រដ្ឋមន្ត្រី ក្រសួងការពារជាតិ រហូត ដល់ឆ្នាំ ១៩៥៥។ នៅឆ្នាំ ១៩៥៧ ទ្រង់ ចូលរួម នៅក្នុង គណៈរដ្ឋមន្ត្រី ដឹកនាំដោយលោក ស៊ឹម វ៉ា ជា រដ្ឋមន្ត្រី ក្រសួង ការពារជាតិ, ព័ត៍មាន និង ទេសចរណ៏។ ចាប់

# លន់ នល់ - សិរិមតៈ ៖ សត្រូវ ឬ មិត្ត ?

ពីឆ្នាំ ១៩៥៨ ទ្រង់ ដកខ្លួន ចេញពីឆាកនយោបាយ រហូតមក ដល់ឆ្នាំ ១៩៦២, ទ្រង់ វិលត្រឡប់មក បំរើ ជាតិវិញ ក្នុង តំណែង ជា អគ្គរាជទូតៈ នៅ ប្រទេស ចិន ប្រជាមានិត (១៩៦៤-១៩៦៦), នៅ ប្រទេស ជប៉ុន (១៩៦៦-១៩៦៧)។ ទ្រង់ វិលត្រឡប់ ចូលស្រុកខ្មែរវិញ ហើយ នៅឆ្នាំ ១៩៦៩ បានចូលរួម ជា សមាជិក នៃ គណៈរដ្ឋមន្ត្រី ដឹកនាំដោយលោក លន់ នល់ ជា ឧបនាយករដ្ឋមន្ត្រី ទី១ ទទួលបន្ទុក ក្រសួង មហាផ្ទៃ, សន្តិសុខ និង កិច្ចការសាសនា។ នៅពេល លោក លន់ នល់ មកព្យាបាល រោគ នៅស្រុកបារាំង, ទ្រង់ សិរិមតៈ រក្សារ៉ាប់រង បណ្តោះអាសន្ន មុខងារ នាយករដ្ឋមន្ត្រី ជំនួស លោក លន់ នល់ ពី ថ្ងៃ ទី៣០ តុលា ឆ្នាំ ១៩៦៩ ដល់ ថ្ងៃ ទី៦ កុម្ភៈ ឆ្នាំ ១៩៧០។ ចាប់ពីឆ្នាំ ១៩៧០ ទ្រង់ សិរិមតៈ ក្លាយ ជា សត្រូវ នយោបាយ នឹង សម្តេច សីហនុ ដែល ជា ហេតុមួយ នៃ ការទំលាក់ សម្តេច សីហនុ ពី តំណែង។ ទ្រង់ ជា តួ ចម្បង មួយ នៃ ការបង្កើត សាធារណរដ្ឋខ្មែរ ទោះបី ទ្រង់ មាន កំណើត នៅក្នុង ព្រះរាជវង្សានុវង្ស។ នៅក្នុង សម័យ សាធារណរដ្ឋខ្មែរ ទ្រង់ ធ្វើ សហការ ជា អចិន្ត្រៃយ៍ នឹង លោក លន់ នល់ រហូត ដល់ នរៈជននេះ ចាកចេញ ពី ស្រុកខ្មែរ នៅ ឆ្នាំ ១៩៧៥។ នៅពេល ដែល ពួក ទាហាន ខ្មែរក្រហម ចូល មក កាន់កាប់ ទីក្រុង ភ្នំពេញ ទ្រង់ សិរិមតៈ ភៀសខ្លួន នៅ ស្ថានទូត បារាំង, ប៉ុន្តែ ពួក ខ្មែរក្រហម ទាមទារ ជា ដាច់ខាត ឱ្យប្រគល់ខ្លួនទ្រង់ ពុំនោះសោត ពួក គេ នឹងវាយ សម្រុក ចូល ទៅចាប់ខ្លួន, ដូច្នេះឯង ទ្រង់ ក៏សុខចិត្ត ចេញ ពី ស្ថានទូត ឱ្យ

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ពួកខ្មែរក្រហម នាំយក ទៅ សម្លាប់ចោល ដែល គ្មាន នរណា ដឹងច្បាស់ ថា នៅ ថ្ងៃណា និង នៅ ទីកន្លែងណា ឡើយ។ ត្រូវ ដឹង ថា មុននឹងអគ្គរដ្ឋទូត សហរដ្ឋអាមេរិកាំង ចាកចេញ ពី ស្រុក ខ្មែរ, លោក បាន ស្នើ ដល់ ទ្រង់ ឱ្យចាកចេញ ពី ជាមួយនឹង គាត់ តែ ទ្រង់ បដិសេធ មិនព្រម រត់ចោល ប្រជាពលរដ្ឋខ្មែរ ដោយ ស្ដីបន្ទោស ដល់ សហរដ្ឋអាមេរិក ថា បោះបង់ចោល ប្រជាពលរដ្ឋខ្មែរ ដែល តែងតែ ទុក សហរដ្ឋអាមេរិក ជា អ្នក ការពារ សេរីភាព ដោយ សេចក្ដីសង្ឃឹម[7]។

---

[7] ន័យ ក្នុង សំបុត្រ របស់ទ្រង់ សិរិមតៈ សរសេរ ជា ភាសា បារាំង ផ្ញើ ចំពោះ លោក អគ្គរដ្ឋទូត សហរដ្ឋអាមេរិក ប្រចាំ នៅ សាធារណរដ្ឋខ្មែរ ដើម្បី បញ្ជាក់ ពី ហេតុផល ដែល ទ្រង់ មិនព្រម ចាកចេញ ពី ស្រុកខ្មែរ ៖

ឯកឧត្ដម និង មិត្តជាទីរាប់អាន,

ខ្ញុំសូមអរគុណចំពោះលិខិត របស់ឯកឧត្ដម និង ការផ្ដល់លទ្ធភាព នាំ ខ្ញុំ ទៅរក សេរីភាព បាន។ ប៉ុន្តែ ខ្ញុំ ពុំអាច ចាកចេញ តាម របៀប កំសាក បែបនេះទេ។ នៅក្នុង ករណី របស់ខ្ញុំ និង ជា ពិសេស ករណី មហាប្រទេស របស់ឯកឧត្ដម, ខ្ញុំ មិនដែល ជឿ មួយភ្លែតណា ថា អ្នក នឹងអាច មាន ដួងចិត្ត បោះបង់ចោល ប្រជាពលរដ្ឋមួយ ដែល ជ្រើស រើស សេរីភាព។ អ្នក បានបដិសេធ ការពារយើង ហើយ យើង ក៏មិន អាចធ្វើអ្វីបានទេ។ អ្នក ចាកចេញ, ខ្ញុំ មានតែ ប្រសិទ្ធពរ ជូនអ្នក និង ប្រទេស របស់អ្នក ទទួលបាន នូវ សុភមង្គល នៅក្រោមវិហាស៍នេះ។ ប៉ុន្តែ សូមអ្នក ជ្រាបជាក់ច្បាស់ ថា ប្រសិនបើ ខ្ញុំ ត្រូវស្លាប់ នៅទីនេះ ភ្លាម និង នៅក្នុង មាតុភូមិ របស់ខ្ញុំ ដែល ជាទីស្រឡាញ់ របស់ខ្ញុំ, មរណៈ ភាពនេះ វា គ្មានអ្វី ជា គរុភាព សំរាប់ ខ្លួនខ្ញុំឡើយ ព្រោះ មនុស្សលោក យើង វា តែងតែ ស្លាប់ នៅថ្ងៃណាមួយ ជា ពុំខាន។ ខ្ញុំ បានប្រព្រឹត្ត តែ កំហុសមួយគត់ គឺ ៈមាន ជំនឿ លើ រូបអ្នក និង ប្រជាជន អាមេរិកាំង។

សូម ឯកឧត្ដម និង មិត្តជាទីរាប់អាន ទទួលយក នូវ អារម្មណ៍ មេត្រី ភាព ដ៏ប្រសើរបំផុត របស់ខ្ញុំ។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត?

## រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ

រាជរដ្ឋាភិបាល « ដោតិ ចុងក្រោយ » ដែល មាន សម្តេច ប៉ែន នុត ជា នាយករដ្ឋមន្ត្រី បាន សុំលាឈប់ពីតំណែង នៅថ្ងៃ ទី ១ មេសា ឆ្នាំ ១៩៦៩។ ហេតុផល គឺ ពុំមាន លទ្ធភាព បន្ត ដោះស្រាយ វិបត្តិ សេដ្ឋកិច្ច ដ៏ធ្ងន់ធ្ងរ ដែល ស្រុកខ្មែរ កំពុង ជួបប្រទះ ចាប់ផ្តើម បន្តិចម្តងៗ តាំង ពី ឆ្នាំ ១៩៦៣ ឆ្នាំ ដែល សម្តេច សីហនុ បដិសេធ ជំនួយ សេដ្ឋកិច្ច និង យោធា អាមេរិកាំង នូវ អនុវត្ត សេដ្ឋកិច្ច សង្គមនិយម។ ហើយ នៅថ្ងៃ ទី៣ មេសា ឆ្នាំ ១៩៦៥ៈ កម្ពុជា ផ្តាច់ការទាក់ទងតាមផ្លូវទូត ជាមួយ អាមេរិកាំង[8]។

ក្រោយមក ពី រដ្ឋាភិបាល ប៉ែន នុត លាលែង, នៅថ្ងៃ ទី ៤ មេសា ឆ្នាំ ១៩៦៩, សម្តេច សីហនុ ធ្វើ សមាជ ពិសេសមួយ អញ្ជើញ ឥស្សរៈជន សំខាន់ៗ ប្រមាណជាង បីរយ នាក់ មកចូលប្រជុំ ដើម្បី ជ្រើសរើស បេក្ខជន នៃ នាយករដ្ឋមន្ត្រី ដើម្បី រៀបចំ បង្កើត រាជរដ្ឋាភិបាល ដែល ព្រះអង្គ ឱ្យឈ្មោះថា « រដ្ឋាភិបាល ស្រោចស្រង់ជាតិ »។ ឥស្សរៈជន ១០ នាក់ ដែល សមាជ ពិសេស បាន ចាត់តាំង ជា បេក្ខជន ហើយ ថ្វាយ លទ្ធភាព ដល់ ព្រះប្រមុខរដ្ឋ ឱ្យជម្រើសយក ឥស្សរជន ណាម្នាក់ ក្នុង ចំណោម

---

បកក្រៅផ្លូវការ

[8] នៅពេលនោះដែរ សម្តេច សីហនុ ស្នើ ដល់ សហរដ្ឋអាមេរិក ឱ្យរក្សាទំនាក់ទំនង នៅត្រឹម កំពស់ ស្ថានកុងស៊ុល, តែ សហរដ្ឋអាមេរិក បដិសេធ។

ឥស្សរជន ១០ នាក់ នោះ។ សម្តេច សីហនុ ទ្រង់ ជ្រើសយក នរោត្តម កន្តុល (១៩២០-១៩៧៦)។ ទ្រង់ កន្តុល ចាប់ផ្តើម ពិគ្រោះ ជាមួយ នយជន[9] មួយចំនួន ដើម្បី រៀបចំ បង្កើត រដ្ឋាភិបាល។ ភាគច្រើន មិនព្រមទទួលសំណើរ របស់ទ្រង់ រួមទាំង លោកឪពុក[10] របស់ខ្ញុំ ដែល ទ្រង់ ស្នើ ក្រសួង ការពារជាតិ ក្នុង ឋានៈ ជា ទេសរដ្ឋមន្ត្រី។ ដូច្នេះ ទ្រង់ កន្តុល មាន ការពិបាក រក ឥស្សរជន សំខាន់ៗ ដើម្បី ចូលរួម ក្នុង រដ្ឋាភិបាល របស់ទ្រង់។ ទ្រង់ បានពិគ្រោះ ជាមួយ សម្តេច ប៉ែន នុត និង នយជន ជា

---

[9] នយជន ៈ អ្នកនយោបាយ។

[10] ឧប គឹម អាង (១៩២២-១៩៧៥), កើត នៅ ស្រុក ក្រចេះ នៅ ខេត្ត តាកែវ, លោក បាន សិក្សា នៅ វិទ្យាល័យ ស៊ីសុវត្ថិ រហូត ដល់ ថ្នាក់ទី១ បន្ទាប់ បាន ប្រឡងប្រជែង ចូលរៀន នៅ សាលា រដ្ឋាបាល, លោក ជ្រើសរើស ផ្នែក រដ្ឋបាល។ ក្រោយ ពីបានបញ្ចប់ សិក្សា ២ឆ្នាំ លោក ត្រូវ បាន ទទួល តំណែង ជា ច្រើន នៅក្នុង រាជការ ៈ ចៅហ្វាយស្រុក នៅ ស្រុក ព្រែកពោ, ក្រូចឆ្មា, កំពង់សៀម, ចៅហ្វាយខេត្ត ស្ទឹងត្រែង, ព្រៃវែង, កំពង់ចាម, នាយកខុទ្ទកាល័យ នៅ ក្រសួង ផែនការ, តំណាងរាស្ត្រ នៅមណ្ឌល ពារាំង ខេត្ត ព្រៃវែង, រដ្ឋលេខា ក្រសួង មហាផ្ទៃ នៅក្នុង រដ្ឋាភិបាល លោក ចៅ សែន កុសល នៅឆ្នាំ ១៩៦៣, រដ្ឋមន្ត្រី ក្រសួង ការពារជាតិ នៅក្នុង រដ្ឋាភិបាល លោក លន់ នល់ នៅឆ្នាំ ១៩៦៥, ឧបនាយករដ្ឋមន្ត្រី ទី៣ ទទួល បន្ទុក ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុង រដ្ឋាភិបាល ស្រោចស្រង់ជាតិ។ នៅក្នុង ចំណោម នៃ ឥស្សជន ១០ នាក់ ដែល សមាជពិសេស ជ្រើសរើស ជា បេក្ខជន នាយករដ្ឋមន្ត្រី មាន ឈ្មោះ លោក ឪពុកខ្ញុំដែរ។
នៅ សម័យ សាធារណរដ្ឋ ៈ សមាជិក រដ្ឋាភិបាល ជា ច្រើនលើក ដូចយ៉ាង ជា ទេសរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ, សន្តិសុខជាតិ និង កិច្ចការ សាសនា, ទេសរដ្ឋមន្ត្រី ក្រសួង សាធារណការ, ដឹកជញ្ជូន។ អគ្គលេខាធិការ នៃ គណបក្ស សាធារណរដ្ឋ, ទីប្រឹក្សា ពិសេស លោក ប្រធានាធិបតី លន់ នល់, នៅឆ្នាំ ១៩៧៥ លោក ជា សមាជិក នៃ គណកម្មការ ជាន់ខ្ពស់ នៃ សាធារណរដ្ឋខ្មែរ។ លោក ត្រូវបាន ពួក ខ្មែរក្រហម សម្លាប់ នៅពេល ដែល ពួកនោះ ចូលមក កាន់កាប់ ទីក្រុង ភ្នំពេញ។

ស់ៗ ហើយនាំគ្នា ថ្វាយដំណឹង ដល់ សម្ដេច សីហនុ ពីការពិត ដោយ ស្មើ ដល់ ព្រះអង្គ ថា មានតែ លោក លន់ នល់ ដែល ជា មនុស្ស អាច ប្រឈរមុខនឹង ស្ថានការបាន។ សំណើរនេះ វា ស្របនឹង សំណើរ របស់ ព្រះមហាក្សត្រីយានី ដល់ សម្ដេច សីហនុ ដែល ទ្រង់ កន្ទល់ យាង ទៅ ទូលថ្វាយ ពី ការបារម្ភ របស់ទ្រង់ ឱ្យជួយ ពន្យល់ សម្ដេច សីហនុ ថា មានតែ លោក លន់ នល់ តែ ប៉ុណ្ណោះ ដែល អាច រៀបចំ បង្កើត រដ្ឋាភិបាល ស្រោចស្រង់ជាតិ បាន។ ដោយ មិនសូវពេញចិត្ត តែ ជា ការចាំបាច់ សម្ដេច សីហនុ ក៏ សម្រេច តែងតាំង លោក លន់ នល់ ជា នាយករដ្ឋមន្ត្រី។ អ្នកទាំងពីរ បានកំណត់រួម ផែនទីបង្ហាញផ្លូវ មាន គម្បដ្ឋាន[11] បី ៖ ស្ដារ សេដ្ឋកិច្ចជាតិ, កំណត់ដោយច្បាស់លាស់ នៃ ខ្សែនយោបាយជាតិ សំរាប់ អនាគត, ពិនិត្យ ឡើងវិញ អំពី ការ ទំនាក់ទំនង ជាមួយ យួនកុម្មុយនិស្ត និង ទំនាក់ទំនងជាថ្មី ជាមួយ សហរដ្ឋអាមេរិក។ ផែនទីបង្ហាញផ្លូវនេះឯង ដែល លោក លន់ នល់ យកទៅស្នើ គៀងគរ ដល់ ទ្រង់ សិរិមតៈ ឱ្យទ្រង់ ចូលរួម នៅក្នុង រដ្ឋាភិបាល ស្រោចស្រង់ជាតិ។ ដើមដំបូង ទ្រង់ សិរិមតៈ មិនសូវ មាន ជំនឿ ប៉ុន្មានឡើយ លើ សុនិតី (bonne foi) របស់ សម្ដេច សីហនុ ថា ព្រះអង្គ នឹងបើកភ្លើងខៀវ ឱ្យលោក លន់ នល់ អនុវត្ត កម្មវិធី នយោបាយ បែបនេះ, តែ លោក លន់ នល់ បាន បញ្ជាក់ហើយ បញ្ជាក់ទៀត ថា សម្ដេច

[11] គម្បដ្ឋាន ៖ ទីដែលគេសំដៅទៅ។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

សីហនុ ព្រះអង្គ មាន ព្រះរាជហឫទ័យ មុតមាំណាស់ ដើម្បី ស្តារ វិបត្តិ សេដ្ឋកិច្ចជាតិ និង ព្រះអង្គ ទទួច ឱ្យមាន ការស្តារ ជាបន្ទាន់ ដំណើរការ នៃ រដ្ឋបាល នៃ ព្រះរាជាណាចក្រ ដែល ព្រះអង្គ មើលឃើញ ថា វា មាន អនាធិបតេយ្យណាស់ សព្វថ្ងៃនេះ ព្រោះ វាមិនដឹង អ្នកណា ធ្វើអ្វី ច្បាស់លាស់ ហើយ អ្នកណា ជាអ្នកទទួលខុសត្រូវ ពិតប្រាកដ។ ព្រះអង្គ បន្ថែមថា ព្រះអង្គ ក៏ដឹងដែរ ថា ខុទ្ទកាល័យ របស់ព្រះអង្គ ក៏មាន ការរំលោភ ច្រើនដែរ ទៅលើ កិច្ចការរដ្ឋ និង រាជរដ្ឋាភិបាល, ដូច្នេះ គួរនឹងតម្រង់ ផ្លូវ ផងដែរ។ លោក លន់ នល់ ជានា បន្ថែម ដល់ ទ្រង់ សិរិមតៈ ថា ទូលបង្គំ នឹងធ្វើគ្រប់បែបយ៉ាង ឱ្យ រដ្ឋាភិបាល រស់រានមាន ជីវិត បានយូរអង្វែង ជា ដាច់ខាត ព្រោះ វា ជា កត្តា នៃ ប្រសិទ្ធិភាព នៅក្នុង សកកម្មភាព ពិសេស ដើម្បី អនាគត នៃ ប្រជាជាតិ។

### ហេតុអ្វី បាន ជា លោក លន់ នល់ ត្រូវការ ទ្រង់ សិរិមតៈ ?

បើមាន វត្តមាន សមាជិក នៃ ព្រះរាជវង្សានុវង្ស វា ជា ទម្ងន់ នយោបាយផង និង ចិត្តសាស្ត្រផង សំរាប់ មតិ មហាជន ហើយ ទ្រង់ សិរិមតៈ ជា ស្តេច សំខាន់ម្នាក់ ដែល ស្តេច ដទៃទៀត មាន ការគោរពណាស់ ហើយ ទ្រង់ ក៏ជា នយជន ដើងចាស់ម្នាក់ មាន ការពិសោធ នយោបាយ ហើយ ក៏មិនមែន ជា មនុស្ស ដែល លោក លន់ នល់ មិនសូវស្គាល់នោះដែរ ព្រោះ ទ្រង់ ក៏ធ្លាប់ ចូលរួម យ៉ាង សកម្ម នៅក្នុង គណបក្ស ខេមរប៉ុន្នការ

## លង់ ណុល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ដែល មាន លោក ជា អ្នកដឹកនាំ។ វត្តមាន របស់ ទ្រង់ សិរិមតៈ ក៏សំរាប់ ធានា សន្តិ (tranquillité) ដល់ ព្រះមហាក្សត្រីយានី ដែល ព្រះអង្គ មាន អានុភាពច្រើន ទៅលើ សម្តេច សីហនុ ជា បុត្រា តែមួយគត់។ មួយវិញទៀត សំរាប់ ធានា ដល់ រដ្ឋសភា ដែល មាន និន្នាការ នៃ សេរីនិយម ព្រោះ ទ្រង់ សិរិមតៈ ជា អវតា នៃ សេរីនិយម។ ដូច្នេះ វត្តមាន ទ្រង់ សិរិមតៈ នៅក្នុង រដ្ឋាភិបាល ជា ការស្វែងរក សមតា ទាំងផ្នែក នយោបាយ ក៏ដូច ផ្នែក ចិត្តសាស្ត្រ នោះឯង។ ជា ទម្លាប់ សម្តេច សីហនុ តែងតែ បញ្ចូល មនុស្សជំនិត របស់ព្រះអង្គ ក្នុង រដ្ឋាភិបាល ដែលព្រះអង្គ ពុំមែនជា នាយករដ្ឋមន្ត្រី, ដូច្នេះ នៅក្នុង រដ្ឋាភិបាល ស្រោចស្រង់ជាតិ មាន លោក អ៊ុំង ហុង សាត ជា ឧបនាយករដ្ឋមន្ត្រី, នរោត្តម ភុរិស្សរា ជា រដ្ឋមន្ត្រី ក្រសួង ការបរទេស, ជួន សៅ ឌី ជា រដ្ឋមន្ត្រី ក្រសួង កសិកម្ម, រុក្ខា និង នេសាទ, ទេព សុី ខេង ជា រដ្ឋលេខាធិការ ក្រសួង ព័ត៌មាន, វរៈសេនីយឯក អ៊ុម ម៉ានូរិន ជា រដ្ឋលេខាធិការ ក្រសួង ការពារ ផ្ទៃដីក្នុងប្រទេស, វរៈសេនីយឯក ស៊ូស្តែន ហ្វែណង់ដែស ជា រដ្ឋលេខាធិការ ក្រសួង សន្តិសុខជាតិ។

### ទំនាស់ សម្តេច សីហនុ នឹង រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ

រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ត្រូវបាន រដ្ឋសភា បោះឆ្នោត ជា ឯកច្ឆន្ទ ផ្តល់ សេចក្តី ទុកចិត្ត លើ សេចក្តីថ្លែងការណ៍ ដោយ នាយករដ្ឋមន្ត្រី ស្តីពី នយោបាយ ទូទៅ និង សមាសភាព នៃ គ

ណៈរដ្ឋមន្ត្រី នៅថ្ងៃ ទី ១២ មេសា ឆ្នាំ ១៩៦៩។ ជា អកុសល លោក លន់ នល់ មាន រោគ ដែល ចាំបាច់ ត្រូ អញ្ជើញ ទៅ ព្យាបាល នៅ ស្រុកបារាំង នៅ ថ្ងៃ ទី ៣០ តុលា ឆ្នាំ ១៩៦៩។ សំនួរ ចំពោះ លោក គឺ ថា បើតាម ទំលាប់ លោក ត្រូវ លាលែងពី តំណែង ដូច លោក ធ្លាប់ បានធ្វើ ម្តងរួចហើយ នៅឆ្នាំ ១៩៦៧ កាលនោះ លោក ក៏ជា នាយករដ្ឋមន្ត្រី មាន របួសធ្ងន់ ដោយ គ្រោះថ្នាក់ រថយន្ត ត្រូវ អញ្ជើញ ទៅ ព្យាបាលខ្លួន នៅ ស្រុកបារាំង។ លើក នេះ មាន ការសន្ទនា ពិសេសមួយ រវាង លោក លន់ នល់ ជាមួយ ទ្រង់ សិរិមតៈ ដែល មាន លោកឪពុកខ្ញុំ[12] ចូលរួមដែរ ៈ

- ទ្រង់ សិរិមតៈ សួរត្រង់ៗ ទៅលោក លន់ នល់ ៈ តើ នល់ ឯង គិត ដូចម្តេច ? លាលែង ពីតំណែង ? បើចាំបាច់សូម នល់

12 លោកឪពុកខ្ញុំ ជា មនុស្សជំនិតនឹងលោក លន់ នល់ ផង និង ទ្រង់ សិរិមតៈ ផង។ លោក ធ្លាប់ ធ្វើ សហការ ជាមួយ តស្សូរជន ទាំងពីរ នៅ ក្នុង គណបក្ស ខេមរៈប៉ុន្នការ។ លោក មាន ទំនាក់ទំនង នឹង តស្សូជន ទាំងពីរនេះ តាម រយៈជីតាខ្ញុំ ខាងម្តាយ (ទេព សុមាលី) ដែល ជា ឪពុក ក្មេង ឈ្មោះ ទេព សំកុល ជា ចៅក្រម នៅ សាលាឧទ្ធរណ៍ ព្រោះ ជីតាខ្ញុំ លោក ជា សមាជិក ស្ថាបនិក នៃ គណបក្ស ខេមរប៉ុន្នការ។ នៅពេល ដែល មាន ការចរចា ជាមួយ លោក ដាប ឈួន, លោក ជា មួយ លោក អ៊ិន តាំ ត្រូវបាន រាជរដ្ឋាភិបាល ជំនាន់នោះ ប្រគល់ បេសកកម្ម ពិសេស និង សម្ងាត់ ជា និរសា (ភ្នាក់ងារ ទំនាក់ទំនង) សំរាប់ ធ្វើការ ទាក់ទង សម្ងាត់ ជាមួយ ដាប ឈួន។ អាជ្ញាធរ បារាំងសែស គេ រកចាប់ នាំ ឱ្យលោក ទាំងពីរ ត្រូវរត់ពួនលាក់ខ្លួន មួយរយៈ។ ត្រូវដឹងថា ស្រុក ខ្មែរ នៅពេលនោះ ពុំទាន់ទទួល ឯករាជ្យ បរិបូណ៌ ពី បារាំង នៅឡើយ, ដូច្នេះ ការចរចា ជាមួយ ខ្មែរតស្សូរៈ ដែល ជា សត្រូវនឹងបារាំង វា ជា ការ សម្ងាត់។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ឯង កុំខ្លាចចិត្តខ្ញុំអ្វីឡើយ, ផ្ញើម៉េច រឿងនេះ វាមិនបាន គ្រោងទុក ហើយ វា ជា រឿង សុខភាព !

លោក លន់ នល់ ឆ្លើយ ជា សំនួរ ៖ តើ ទ្រង់ យល់យ៉ាងដូចម្ដេច ដែរ បើ ខ្ញុំ ពុំលាលែង តើ រដ្ឋសភា មាន ប្រតិកម្ម បែបណាដែរ ហើយ សម្ដេច ព្រះអង្គ យល់ព្រមដែរឬទេ ?

- ទ្រង់ សិរិមតៈ មាន បន្ទូលតបវិញ ៖ ចំពោះខ្ញុំ រដ្ឋសភា មិន មាន ប្រតិកម្ម អវិជ្ជមាន នោះឡើយ ព្រោះ គំរោង នៃ សេដ្ឋកិច្ច ដែល យើង នឹងដាក់ ជូន រដ្ឋសភា, បើតាម គឹម អាង ដែល បាន ពិភាក្សា ក្នុង គណកម្មាធិការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ វា ហាក់បី គ្មាន ការពិបាកធំដុំ ដែល រដ្ឋ សភា មិន បោះឆ្នោតឱ្យនោះទេ។ រីឯ ប្រតិកម្ម របស់ ស ម្ដេច ខ្ញុំ យល់ឃើញ ថា ព្រះអង្គ មិនមាន បំណង នឹង រំលំ រដ្ឋាភិបាលយើង ភ្លាមៗដែរ ទោះយ៉ាងណា ក៏ ព្រះអង្គ រង់ ចាំ ប្រតិកម្ម រដ្ឋសភា នៅចំពោះមុខ គំរោង សេដ្ឋកិច្ច សេរី របស់យើង។ បើ គំរោងយើង រដ្ឋសភា បដិសេធ ពេល នោះ ព្រះអង្គ យល់ឃើញថា ច្បាស់ ជា រដ្ឋាភិបាល នឹង សូម លាលែង ជាពុំខាន ឬ ក៏ញុះញង់ឱ្យ រដ្ឋសភា រំលំ រដ្ឋាភិបា ល។ បើ នល់ ឯង ទុកចិត្ត លើខ្ញុំ ខ្ញុំ នឹងបន្តកិច្ចការនេះ រហូតដល់ពេលនោះ ព្រោះ ដំណើរ របស់យើង វា បាន វែង ឆ្ងាយ ណាស់ដែរហើយ, ហើយ យើង ចាំគិតអ្វីៗបន្តទៀត។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

- លោក លន់ នល់ ឆ្លើយតបៈ ចំពោះខ្ញុំ បើ មិនរំខាន ដល់ ទ្រង់ វា គ្មាន ហេតុផលអ្វី ដែល ខ្ញុំ មិនទុកចិត្តទ្រង់នោះ ឡើយ។ ទ្រង់ មានព្រះទ័យ សុខចិត្ត ចូលរួម ក្នុង រដ្ឋាភិបា ល ជា កិត្តិយសមួយ ដល់ទូលបង្គំ ណាស់ទៅហើយ។ ដូច្នេះ យើង មិនត្រូវ ធ្វើឱ្យ សហការយើង វា ចប់ សោះកក្រោះ បែបនេះឡើយ។ ទូលបង្គំ យល់ឃើញថា យើង ត្រូវតែ បន្ត ធ្វើអ្វី ដែល យើង ត្រូវធ្វើ ទោះបី គ្មាន វត្តមាន ទូលបង្គំ មួយរយៈ ក៏ដោយ។ ទ្រង់ មាន ឥស្សរជន ឆ្នើមៗ នៅក្នុង រដ្ឋាភិបាល ដែល ខ្ញុំ ទុកចិត្ត និង ជា សេចក្តីសង្ឃឹម ទៀត ផង បន្ត ជួយ ទ្រង់ ក្នុង បេសកកម្ម ដ៏ពិបាកមួយ តែ គួរ តែធ្វើ ព្រោះ ជា អំពើ ស្រោចស្រង់ជាតិ តាម រាជបំណង របស់ សម្តេច។ ដូច្នេះ ទ្រង់ បន្ត កាន់មុខដំណែង ជំនួស ទូលបង្គំ ជា ប្រតិភូ នាយករដ្ឋមន្ត្រី ដែល អនុញ្ញាត ឱ្យ រដ្ឋា ភិបាលបន្ត សកម្មភាព ជាធម្មតា មិនចាំ ទៅសូម សេច ក្តីទុកចិត្ត ជា ថ្មីម្តងទៀត ពី រដ្ឋសភា ព្រោះ អវត្តមាន ទូល បង្គំ វា មាន លក្ខណៈ បណ្តោះអាសន្ន។

ការសន្ទនា ដ៏សាមញ្ញមួយនេះ បង្ហាញ នូវ សហចិត្ត រវាង លោក លន់ នល់ និង ទ្រង់ សិរិមតៈ នៅពេលនោះ ដែល ជា កម្លាំង សំ រាប់ រដ្ឋាភិបាល បន្ត បេសកកម្ម នៃ ការស្រោចស្រង់ជាតិ ដែល សម្តេច សីហនុ ខ្លួនឯង ជា អ្នកកំណត់ឱ្យធ្វើ។ ការសម្រេច របស់លោក លន់ នល់ លើ រឿងនេះ គឺបញ្ជាក់ថា នៅពេល លោក ចូលគាល់ សម្តេច សីហនុ ដើម្បីថ្វាយ ដំណឹង អំពី អាការរោគ

របស់លោក, លោក មិនបាន លើកយក បញ្ហា លាលែងពីតំណែង មក ពិគ្រោះ ជាមួយ សម្តេច នោះដែរ ហើយ សម្តេច ក៏មិនយករឿងនេះ មក និយាយដែរ។ សួរថា តើ ជា ការនៅស្ងៀម ជា ការគួរសម ឬ ជា យុទ្ធសាស្ត្រនយោបាយ ? ត្រូវដឹងថា សម្តេច សីហនុ ព្រះអង្គ គោរពរាប់អានលោក លន់ នល់ ទុកលោក ជា មនុស្ស ដ៏ទុកចិត្តម្នាក់ ក្នុង ចំណោម មនុស្ស មួយក្រុម ដែល ព្រះអង្គ ទុក ជា មនុស្ស ជំនិតនឹងព្រះអង្គ។

ដូច្នេះ គួរ ពិនិត្យ លើ សកម្មភាព នៃ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ថា ហេតុអ្វី បាន ជា សម្តេច សីហនុ ព្រះអង្គ ទុក សកម្មភាពនោះ ជា ការប្រឆាំងនឹង ព្រះអង្គ តែម្តង។

## សកម្មភាព នៃ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ

រាជរដ្ឋាភិបាល មាន គោលការណ៍ ធ្វើសោធនកម្ម[13] ថវិកាជាតិ ព្រោះ ថា ពន្ធដារ ក្នុង វិស័យ ការដឹកនាំ ដែល ត្រូវចូល ក្នុងហិប ថវិកាជាតិ ត្រូវបាន ផ្ទេរ ដោយផ្ទាល់ គ្មានច្បាប់ ទៅក្នុងហិបប្រាក់ ពិសេស របស់ ព្រះប្រមុខរដ្ឋ ហើយ លើសពីនេះទៀត ក្រសួង និមួយៗ ត្រូវកាត់យកមួយចំណែក ថវិកា ក្រសួង សំរាប់ ផ្ទេរ ទៅ ហិបប្រាក់ ពិសេសនោះ។ ទង្វើ ឥតច្បាប់នេះ នាំឱ្យ រាជរដ្ឋាភិបាល មាន គោលការណ៍ លុបចោល ព្រោះ វា ផ្ទុយនឹងប្រយោជន៍ជាតិ, ដូច្នេះ ក្រសួង ថវិកាជាតិ ដែល ស្ថិតនៅក្រោម

[13] សោធនកម្ម : ការជម្រះ, ការលាងជម្រះ, ការស្អាត, ការជម្រះអោយត្រឹមត្រូវ។

# លង់ ឆល់ - សេរីមតៈ : សត្រូវ ឬ មិត្ត ?

ក្រសួង សេដ្ឋកិច្ចជាតិ និង ហិរញ្ញវត្ថុ បាន ផ្ញើ សារាចរ ក្រសួង ចំពោះ ព្រះខុទ្ទកាល័យ នៃ ព្រះប្រមុខរដ្ឋ និង គ្រប់ ក្រសួង នានា ដើម្បី ជូន ជា ដំណឹង នូវ ការលុបចោល នៃ ការអនុវត្ត ន៍នោះ។ គោលដៅ គឺ ស្វែងរក ការចាត់ចែង ថវិកា ឱ្យមាន ប្រសិទ្ធិភាព។ ពិតប្រាកដណាស់ ក្រសួង ថវិកាជាតិ នឹងផ្តល់ ថវិកា ដល់ ព្រះខុទ្ទកាល័យ ទៅតាម តម្រូវការ របស់ ព្រះ ប្រមុខរដ្ឋ តែ ការផ្គត់ផ្គង់នោះ ត្រូវធ្វើ នៅក្នុង ក្របខណ្ឌ ថវិកា ជាតិ មានច្បាប់ត្រឹមត្រូវ។ លោកឱពុកខ្ញុំ ដែល ឧបនាយករដ្ឋ មន្ត្រី ទទួល បន្ទុក ក្រសួង សេដ្ឋកិច្ចជាតិ និង ហិរញ្ញវត្ថុ ហើយ ជា ហត្ថលេខី នៃ សារាចរនោះ បានទទួល លិខិតមួយ ដែល មាន ព្រះសង្ហារ នៃ សម្តេច ព្រះប្រមុខរដ្ឋ ដែល នៅលើ ក្រដាស សំបុត្រនោះ គ្មាន សេសេរ តែមាន បិទ ដោយ ការបិទ មមិស គឺ មាន ន័យ ថា « ស៊ីក្តអញ ! »។ ចំណែក ក្រសួង មហាផ្ទៃ ក៏មាន ចេញ សារាចរមួយ ដល់ គ្រប់ អភិបាលខេត្ត និង នាយកដ្ឋាន រដ្ឋបាល សំខាន់ៗ នៅក្នុង ព្រះរាជាណាចក្រ ប្រាម មិនឱ្យ មាន ទំនាក់ទំនងផ្ទាល់ ជាមួយ ព្រះខុទ្ទកាល័យ នៃ ព្រះប្រមុខរដ្ឋ ពាក់ព័ន្ធនឹង កិច្ចការ រដ្ឋបាល។ សារាចរនេះ គឺ ធ្វើឡើង នៅ ក្នុង គោលដៅ សំរាប់ ស្តារ ការទំនាក់ទំនង រដ្ឋបាល ជា ប្រក្រតី រវាង រាជរដ្ឋាភិបាល ជាមួយ រដ្ឋបាលខេត្ត ដើម្បី ប្រសិទ្ធិភាព នៃ កិច្ចការរដ្ឋ នៅក្នុង ព្រះរាជាណាចក្រ។ នៅក្នុង កំណែទំរង់ សេដ្ឋ កិច្ច, រាជរដ្ឋាភិបាល មាន គំរោង ធ្វើសេរីកម្ម វិស័យ ធនាគារ និង ធានារ៉ាប់រង ដើម្បី ទាក់ទាញ មូលធន បរទេស ដើម្បី ធ្វើ

# លន់ នល់ - សិរិមតះ : សត្រូវ ឬ មិត្ត ?

អភិវឌ្ឍន៍ ក្នុង វិស័យ កសិកម្ម និង ឧស្សាហកម្ម រូបបរិវត្ត នៃ រូបធាតុដើម ដើម្បី បន្ថយ ការនាំចូល ទំនិញ ចាំបាច់ សំរាប់ ការរស់នៅ។ នៅក្នុង ការប្រយុទ្ធ ប្រឆាំងនឹង ការរត់ពន្ធ អង្ករ, រាជរដ្ឋាភិបាល សម្រេច ប្តូរ ក្រដាសប្រាក់ ៥០០ រៀល ដែល កង ទ័ព យៀកកុង មាន ច្រើនណាស់ ជា លុយពិត និង ក្លែងក្លាយ សំរាប់ លួចទិញ អង្ករ សំរាប់ ចិញ្ចឹម កងទ័ពគេ រស់នៅ ក្នុង ស្រុកខ្មែរក្តី នៅស្រុកយួនក្តី ពី ក្រុមហ៊ុនខ្មែរ និង ប្រជាកសិករ ក្នុង តម្លៃខ្ពស់មួយ ដែលនាំឱ្យ តម្លៃអង្ករ ឡើងថ្លៃ ជា អតិបរមា ដែលនាំឱ្យ ខ្វះ អង្ករ សំរាប់ ការបរិភោគ ក្នុងស្រុក។ ការប្តូរនោះ គឺ ធ្វើដោយប្រញាប់បំផុត ដើម្បី កុំឱ្យ ពួក យៀកកុង មាន លទ្ធភាពនឹងអាច ប្តូរឱ្យទាន់ពេលវេលា។

សម្តេច សីហនុ គ្មាន ប្រតិកម្ម ជាក់ស្តែង លើ សកម្មភាព របស់ រដ្ឋាភិបាល, ប្រហែល ជា ព្រះអង្គ មិនចង់ ឱ្យមាន ទំនាស់ នឹង ការសន្យា របស់ ព្រះអង្គ ជាមួយ លោក លន់ នល់។

## ជំហរ នៃ រដ្ឋសភា

សួរថា តើ រដ្ឋសភា មាន ជំហរ បែបយ៉ាងណា ចំពោះ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ? គួរលើកមកពិនិត្យ អំពី សមាសភាព នៃ រដ្ឋសភា នៅ ជំនាន់នោះ ថា ជា រដ្ឋសភា បែបណា។

នៅឆ្នាំ ១៩៦៦ ដែល ជា ឆ្នាំ ដែល សម្តេច សីហនុ ធ្វើ សេរីកម្ម ការបោះឆ្នោត ដោយ យក គោលការណ៍ នៃ បេក្ខភាព សេរី នៅ

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ក្នុង ក្របខណ្ឌ សង្គម[14]។ សេរីកម្ម នេះ បណ្តា ឲ មាន កម្មវិបាក ដល់ សម្តេច សីហនុ ព្រោះ វា នាំ បង្កើត កម្លាំងនយោបាយ ស្វយ័ត នៅ រដ្ឋសភា[15] ដែល ជា កម្លាំង មាន ទំនាស់ ផ្ទាល់នឹង ព្រះអង្គ។ នៅ ចំពោះ មុខ សញ្ញា នេះ សម្តេច សីហនុ ទ្រង់ បាត់ សេចក្តីឈ្លាតវៃ នយោបាយ, ទ្រង់ មិនគិត រក មធ្យោបាយ ធ្វើ សហការ ជា មួយ រដ្ឋសភា ដែល កើតឡើង ពី ឆន្ទៈល្អប្រសើរ

---

[14] យើង ដកស្រង់ ព្រះសុន្ទរកថា នៃ សម្តេច សីហនុ ទ្រង់ ថ្លែង ទៅកាន់ រដ្ឋសភា កើតចេញ ពី សេរីកម្ម នៃ ការបោះឆ្នោត :

« ...វាចា ជា បឋម របស់ ខ្ញុំ គឺ ខ្ញុំ ថ្លែង ជូន សហជីវិនី សហជីវិន នូវ សេចក្តីសរសើរ យ៉ាងខ្លាំង ចំពោះ និង យ៉ាងខ្លាំងក្លា បំផុត របស់ ខ្ញុំ។ សហជីវិនី សហជីវិន ជា តំណាងរាស្រ្ត របស់ប្រជារាស្រ្តខ្មែរ ដោយ យថាហេតុ មិនមែន ដូចអ្នកតំណាងរាស្រ្ត មុនៗ ដែល ជា បេក្ខជន ដែល គណកម្មធិការ នាយក សង្គមយើង ចាត់តាំង ហើយ ដែល អ្នកបោះឆ្នោត ភាគច្រើន បញ្ចេញមតិ យល់ព្រម នោះទេ។ ហេតុនេះ អត្ថន័យ នៃ អាណត្តិ របស់ សហជីវិនី សហជីវិន មាន ភាពរឹងប៉ឹង រក អ្នកណា ជំទាស់ ពុំបាន ដោយ ហេតុថា ជនរួមជាតិ នៃ យើង មាន សេរីភាព ពេញទី ក្នុង ការជ្រើសរើស។
ខ្ញុំ សូមសរសើរ ផងដែរ ចំពោះ អ្នកបោះឆ្នោត ទូទៅ ដែលបាន បញ្ចេញ ឲឃើញ ការផ្ចិនផ្ចៅ ខាង នយោបាយខ្លួន ដោយ នាំគ្នា ទៅ បោះឆ្នោត ក្នុង សេចក្តីរៀបរយ និង ដោយ គោរពវិន័យ នៃ ពលរដ្ឋ។ ប្រទេសយើង ដែល បានបង្ហាញ ឲឃើញ នូវ ដំណើរ នៃ លទ្ធិប្រជាធិបតេយ្យ ពិតប្រាកដ បែបនេះ អាច មាន សេចក្តីឆ្ងើង បាន ដោយ សមហេតុផល នៅពេល ដែល ពួក មហាអំណាច ក្នុងលោក ដែល តាំងខ្លួន ជា សេរី នោះ ហ៊ាន លើក យក មក ធ្វើ ជា ឧទាហរណ៍ នូវ ការបោះឆ្នោត បន្លំ ដែល របបគ្រប់គ្រង នៃ ព្រៃនគរ រៀបចំប្រឌិត ឡើង។ ក៏ប៉ុន្តែ យើង មិនត្រូវ ភ្លេច ឲសោះ ថា លទ្ធិប្រជាធិបតេយ្យខ្មែរ នេះ ដែល ខ្ញុំ ប្រឹងប្រែង សម្រឹតសម្រាំង និង ជាទី សង្ឃឹម របស់ ខ្ញុំ អាចរស់បាន មកទល់នឹង ពេលនេះ ហើយ អាចមាន លក្ខណៈ បែបនេះ បាន គឺ ដោយសារ សង្គម យើង... »

[15] លោកឪពុកខ្ញុំ លោក បាន ជាប់ឆ្នោត ជា ថ្មី នៅក្នុង រដ្ឋសភានោះ ជា តំណាងរាស្រ្ត នៅមណ្ឌល ពារាំង ស្រុក ស្វាយពល ក្នុង ខេត្ត ព្រៃវែង។

## លន់ នល់ - សេរីមតៈ : សត្រូវ ឬ មិត្ត ?

របស់ព្រះអង្គ, បែរ ជា គិត តែ រក មធ្យោបាយ ប្រឆាំង យកឈ្នះ ដាច់ខាត នឹងអ្វី ដែល ទ្រង់ ទុក ផ្កាប់មុខ ជា ការគំរាម ដល់ ព្រះអង្គ។ ព្រះអង្គ បង្កើត បរិវាជរដ្ឋាភិបាល និង គណកម្មការ ពិសេស ដើម្បី ត្រួតពិនិត្យ លើ សកម្មភាព រាជរដ្ឋាភិបាល ដែល វា ជា តួនាទី របស់ រដ្ឋសភា សុទ្ធសាធ។ ជាការពិត រដ្ឋសភានោះ មាន កេរ៍ឈ្មោះ ថា ជា រដ្ឋសភា មាន និន្នាការ សេរីនិយម ហើយ មាន តំណាងរាស្ត្រ មួយចំនួន ដែល សម្តេច សីហនុ ទុក ជា សត្រូវ នយោបាយ ព្រោះ ហ៊ានឈ្លោះ ចេញមុខនឹងព្រះអង្គ ដូច ជា លោក ឌុក រ៉ាស៊ី, ស៊ឹម វ៉ា ដែល ព្រះអង្គ ទុក ជា ប្រមុខ នៃ ពួក អ្នកស្តាំនិយម, លោក ខៀវ សំផន, ហ៊ុយ នឹម, ហ៊ូ យន់ ដែល ព្រះអង្គ ទុក ជា ពួក កុម្មុយនិស្ត។ ជម្លោះនោះឯង ដែល ជា ហេតុ ដែល នាំឱ្យព្រះអង្គ រំលាយ រដ្ឋសភាមុន ហើយ ធ្វើ សេរីកម្ម នៃ ការបោះឆ្នោត រើស តំណាងរាស្ត្រ ថ្មី ដោយ សង្ឃឹម ថា ច្បាស់ ជា ប្រជារាស្ត្រ មិន ជ្រើសរើស ពួក សត្រូវ របស់ព្រះអង្គ ទាំងនោះ ដាច់ខាត ព្រោះ ពុំមែន ជា បេក្ខជន ដែល ចលនា សង្គមរាស្ត្រនិយម បានធ្វើជម្រើស។ លទ្ធផល វា ផ្ទុយ ពី បំណង របស់ព្រះអង្គ ចង់បាន ព្រោះ អ្នកទាំងនោះ ត្រូវបាន ប្រជារាស្ត្រ បោះឆ្នោតឱ្យ ជាថ្មី ហើយ តំណាងរាស្ត្រ ដទៃទៀត ជាប់ឆ្នោត ដោយ មាន អារម្មណ៍ ប្រកបទៅដោយ មោទនភាព ថា ខ្លួន ជា តំណាង ពិតប្រាកដ ដោយសារ ខ្លួន ជា បេក្ខជន សេរី ទោះបី ខ្លួន ជា សមាជិក នៃ ចលនា សង្គមរាស្ត្រនិយមក្តី តែ ប្រជារាស្ត្រ ជា អ្នកបោះឆ្នោត រើសខ្លួនផ្ទាល់ ដោយ មិនចាំបាច់ មាន

# លង់ ឆលំ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ការរើសសម្រាំង ជាមុនពីសំណាក់ ចលនាសង្គមរាស្ត្រនិយម នោះឡើយ។ ដូច្នេះ កាតព្វកិច្ច គឺ បំរើ ផលប្រយោជន៍ នៃ ប្រជារាស្ត្រ។ មើល ឃើញច្បាស់ ថា ស្រុកខ្មែរ មាន វិបត្តិ សេដ្ឋកិច្ច ជ្រៅ ហើយ ចំបាច់ ត្រូវមាន កំណែទំរង់មូល, តំណាងរាស្ត្រ ភាគច្រើន ដាច់ខាត គាំទ្រ គំរោង នៃ កំណែទំរង់ សេរីកម្ម សេដ្ឋកិច្ច របស់ រាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ហើយ បោះឆ្នោត ឱ្យ សុពលភាព ដល់ រដ្ឋាភិបាល ដើម្បី អនុវត្ត កំណែទំរង់នោះ។ ការណ៍នេះ នាំឱ្យ សម្ដេច សីហនុ ក្រែវក្រោធ ព្រោះ ជា ការប្រឆាំងនឹង ទ្រឹស្ដី សេដ្ឋកិច្ច សង្គមនិយម របស់ព្រះអង្គ។ ព្រះអង្គ ប្រកាស ជា សាធារណ: ថា ព្រះអង្គ ទុក រដ្ឋសភានោះ ជា សត្រូវនយោបាយនឹង ព្រះអង្គ ហើយ បញ្ឈប់ ទំនាក់ទំនង ជាមួយ រហូត ប្រកាសថា ព្រះអង្គ ប្រាម ពួក តំណាងរាស្ត្រ មិនឱ្យ ចូលរួម ក្នុង សមាជ ជាតិ ដែល គ្រោង ធ្វើ នៅ ខែ ធ្នូ ឆ្នាំ ១៩៦៩។

## សមាជជាតិ ចុងក្រោយ

ដោយ តក្កភាព (logiquement) កំហឹង សម្ដេច សីហនុ នឹង រដ្ឋសភាក៏វា កើតមក ពី គំរោង របស់ រដ្ឋាភិបាល មួយចំណែកដែរ, ដូច្នេះ ច្បាស់ជា ព្រះអង្គ មិនចង់ ឱ្យ រដ្ឋាភិបាល, ជា ពិសេស ដឹកនាំ បណ្ដោះអាសន្ន ដោយ ទ្រង់ សិរិមតៈ, ចូលរួមក្នុង សមាជជាតិ។ ចំពោះ ព្រះអង្គ, សិរិមតៈ ជា មនុស្ស ឱកាសនិយម ហើយ គ្មាន ជម្មាន្សរូប កាន់ដំណែង ជា ប្រតិភូ នាយករដ្ឋមន្ត្រី។ ព្រះអង្គ ត្រូវរក ក្រឡេច ធ្វើឱ្យ រដ្ឋាភិបាលនេះ លា

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

លែង ពីតំណែង មុន សមាជជាតិ។ ឧបាយកល របស់ព្រះអង្គ គឺ មានតែឱ្យរដ្ឋមន្ត្រី ដែល ជា មនុស្សជំនិតនឹង ព្រះអង្គ លាលែង ពីតំណែង៖ លោក អ៊ឹង ហុង សាត ជា ឧបនាយករដ្ឋមន្ត្រី, នរោត្តម ភុរិស្សារា ជា រដ្ឋមន្ត្រី ក្រសួង ការបរទេស, ជួន សៅ ឌី ជា រដ្ឋមន្ត្រី ក្រសួង កសិកម្ម, រុក្ខា និង នេសាទ, ទេព ស៊ី ខេង ជា រដ្ឋលេខាធិការ ក្រសួង ព័ត៌មាន។ រីឯ វរៈសេនីយឯក អ៊ុម ម៉ានូរិន ជា រដ្ឋលេខាធិការ ក្រសួង ការពារ ក្នុងផ្ទៃប្រទេស និង វរៈសេនីយឯក ស៊ូស្តែន ហ្វែណង់ដែស ជា រដ្ឋលេខាធិការ ក្រសួង សន្តិសុខជាតិ ព្រះអង្គ មិនឱ្យ លាលែង ដើម្បី រក្សា សន្តិសុខ ព្រះអង្គ។ ទ្រង់ យល់ឃើញ ថា ចំនួន បួន រដ្ឋមន្ត្រី វា អាច ធ្វើឱ្យ រដ្ឋមន្ត្រី មួយចំនួនទៀត នឹងលាលែង ពី ដំណែង ដោយ មាន ភក្តីនឹង ព្រះអង្គ, បន្ទាប់មក គណរដ្ឋមន្ត្រី ច្បាស់ ជា លាលែង ដោយ ខ្វះ ភាពរឹងមាំ និង សាមគ្គីភាព។ សមយុទ្ធនេះ ពុំបាន នាំឱ្យមាន ការលាលែង បន្ថែមទៀតឡើយ ហើយ មិន អង្រួន សេចក្តីប្តេជ្ញាចិត្ត របស់ទ្រង់ សិរិមតៈ, ទ្រង់ ផ្ទេរ ដំណែង ទំនេរ ទាំងឡាយនោះ ទៅឱ្យ រដ្ឋមន្ត្រី ក្រសួង ផ្សេងៗទៀត កាន់កាប់ ជា បណ្តោះអាសន្ន ដោយ រង់ចាំ ការវិលត្រឡប់លោក លន់ នល់ មក ស្រុកខ្មែរ វិញ។ ទង្វើនេះ មានតែ រដ្ឋសភា អាចជំទាស់បាន បើមានចំនួន តំណាងរាស្ត្រ គ្រប់គ្រាន់ កំរិតដោយច្បាប់ ដាក់ ញត្តិ ចាប់ពិរុទ្ធ ស្នើឱ្យមាន ការបោះឆ្នោត ដកសេចក្តីទុកចិត្ត ពី រដ្ឋាភិបាល។ នៅខាង រដ្ឋសភា គ្មានប្រតិកម្មអ្វី ប្រឆាំងនឹង ទង្វើ របស់ រដ្ឋាភិបាលនោះឡើយ។ ដូច្នេះ ការប្រទល់មុខគ្នា

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

រវាង រដ្ឋាភិបាល ដឹកនាំដោយ ទ្រង់ សិរិមតៈ នឹង សម្ដេច សីហនុ នៅក្នុង សមាជជាតិ ទី ២៨ នៅ ខែ ធ្នូ ឆ្នាំ ១៩៦៩ វាមិនអាចជៀសវាង បាននោះឡើយ។ នៅពេលនោះ ផែនការ នៃ សេរីកម្មវិស័យ ធានាគារ និង ធានារ៉ាប់រង ត្រូវ សម្ដេច សីហនុ លើកយកមកដាក់ជូន សមាជាតិ ឱ្យពិនិត្យពិច័យ គ្រប់ជ្រុង ហើយវាគ្មិន ស្ម័គ្រគពួក របស់ព្រះអង្គ ឡើងនិយាយ លើ វេទិកា សំរាប់សាធារណជន រិះគន់ គ្មាន សំចៃមាត់, តែ ទ្រង់ សិរិមតៈ និងលោកឪពុកខ្ញុំ ឆ្លើយ ពន្យល់ យ៉ាងល្អិតល្អន់ គ្រប់ ចំណុច នៃ សំនួរ និង ការរិះគន់។ ការប្រយុទ្ធ គំនិត និង គំនិត, សុរោហារនិង សុរោហារ រវាង ភាគី រដ្ឋាភិបាល នឹង ភាគី សម្ដេច សីហនុមាន តាំង ពី ថ្ងៃ ដំបូង នៃ សមាជ រហូត ដល់ ថ្ងៃ ទីចប់ គឺ ថ្ងៃទី២៧ រហូត ដល់ ថ្ងៃ ទី៣០ ធ្នូ។ តាម ធម្មតា នៅក្នុង វិប្រតិបត្តិខ្លាំងបែបនេះ, សម្ដេច  អាច ស្នើ ដល់ សមាជជាតិ ឱ្យធ្វើ ការសម្រេច ជា សំណើរ ស្នើ ដល់ រដ្ឋសភា ដើម្បី ឱ្យស្ថាប័ននេះសម្រេច តាម ការបោះឆ្នោត យក បញ្ហានោះ ដាក់ជូន ប្រជាពលរដ្ឋ ធ្វើប្រជាមតិ។ តែ នៅពេលនោះ ព្រះអង្គ គ្មានប្រតិកម្មប្រហែល ដោយសារ ព្រះអង្គ បារម្ភ ថា រដ្ឋសភា នឹង បោះឆ្នោតប្រឆាំងនឹង ការស្នើ ឱ្យមាន ការធ្វើ ប្រជាមតិ។ ដូច្នេះ នៅក្នុងអារម្មណ៍ របស់ មហាជន គាត់ ទុក រដ្ឋាភិបាល ជា អ្នកឈ្នះនយោបាយ លើ សម្ដេច សីហនុ។ ហើយ នៅក្នុង គំនិតនេះឯងដែល សម្ដេច សីហនុ ព្រះអង្គ យាង ចាកចេញ ពីស្រុកខ្មែរ តាមការហោះហើរ តាមពេលវេលាកំណត់ នៃ យន្តហោះ AIR FRANCE

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

នៅថ្ងៃ ទី៦ មករា ឆ្នាំ ១៩៧០ នៅ ពេលរាត្រី ដោយ គ្មានជូន ដំណឹង ជាមុន ដល់ រាជរដ្ឋាភិបាល។ ការចាកចេញនេះ ជា អាថ៌ កំបាំងមួយ ដែល អ្នកភ្នំពេញ គ្រប់ មជ្ឈដ្ឋាន នាំគ្នា ខ្សឹបខ្សៀវ គ្នា រក ហេតុផល។

## ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០

នៅទីនេះ យើង មិនលើកយក ដំណើរ ការណ៍ នយោបាយ បន្ត បន្ទាប់គ្នា ដែល នាំ បង្កើត ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា នោះទេ ព្រោះ វា មិនមែន ជា ប្រធានបទ ដែល យើង លើកមក ពិពណ៌នា គឺគោលជំហរ របស់លោក លន់ នល់ និង ទ្រង់ សិរិម តៈ នៅក្នុង ដំណើរ ការណ៍នោះ ដើម្បី ឆ្លើយនឹង សំនួរ ថា តើ លោក លន់ នល់ និង ទ្រង់ សិរិមតៈ ជា សត្រូវ ឬ ជា មិត្ត នឹង គ្នា ? គេ តែងតែ សួរ ថា តើ អ្នកណាមួយ ជា តួឯក នៅក្នុង រឿង ទំលាក់ សម្ដេច សីហនុ ពី មុខដំណែង ? គេ បង្កើត សាច់ រឿង (scénario) មួយចំនួន ដើម្បី ឆ្លើយនឹង សំនួរ, អ្នកខ្លះ ថា លោក លន់ នល់ ជា តួឯក អ្នកខ្លះទៀត ថា ទ្រង់ សិរិមតៈ ទេ។ ដូច្នេះ មានតែ ពិនិត្យពិច័យ លើ គោលជំហរ របស់ លោក ទាំង ពីរ ប្រហែល ជាអាច បង្ហាញ ពី តួនាទី រៀងៗខ្លួន និង បំពេញ បន្ថែម រវាងគ្នា នៅក្នុង បរិស្ថាន នយោបាយ ក្ដៅ គគុក ដែល វា បង្កើត ជា បក្សពួក បដិបក្ខ ឬ សត្រូវនឹងគ្នា នៅ ជុំវិញ តួ ចម ទាំងពីរនាក់នោះ។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

## គោលជំហរ របស់ទ្រង់ សិរិមតៈ

ទ្រង់ សិរិមតៈ ជា ស្តេចមួយអង្គ, នៅក្នុង ប្រវត្តិសាស្ត្រខ្មែរ ជម្លោះ ស្តេចមួយអង្គ នឹង ស្តេច គ្រងរាជ្យសម្បត្តិ វា ជា ទម្លាប់ ធម្មតា ដែល មានកើតឡើង រឿយៗ នៅក្នុង ព្រះរាជវង្សានុវង្ស ខ្មែរ។ លោក លន់ នល់ នៅពេលដើមដំបូង នៃ វិបត្តិ នយោបាយ ជាមួយ សម្តេច សីហនុ ក៏ ធ្លាប់ រំឭក ដល់ ទ្រង់ សិរិមតៈ ពី ការបារម្ភ របស់លោក ពី ទម្លាប់នោះដែរ។ ត្រូវដឹងដែរ ថា ទ្រង់ សិរិមតៈ នៅពេល ដែល ហ្លួង ស៊ីសុវត្ថិ មុនីវង្ស ចូលទីវង្គត ទ្រង់ ក៏ជា ស្តេចមួយអង្គ មាន ឈ្មោះ នៅក្នុង តារាង នៃ ស្តេចមួយចំនួនតូច ដែល ក្រុមប្រឹក្សា ព្រះរាជបល្ល័ង្ក សម្រាំង សំរាប់ ដាក់ជូន ក្រុមជំនុំ ដើម្បី បោះឆ្នោត ជ្រើសរើស ព្រះមហាក្សត្រ បន្ត រាជ្យ, ចំណែក សម្តេច សីហនុ វិញ ឈ្មោះ ព្រះអង្គ គ្មាន នៅក្នុង តារាង នោះឡើយ។ ក្នុង ចំណោម ស្តេច ទាំងនោះ ក្រុមប្រឹក្សា ព្រះរាជបល្ល័ង្ក និង ព្រះសង្ឃរាជ្យ ទាំង ពីរ និកាយ បាន ជ្រើសរើស ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ដែល ជា ព្រះបុត្រាច្បង នៃ លួង សុវណ្ណកោត មុនីវង្ស ឱ្យ គ្រងរាជ្យ បន្ត ពី ព្រះបិតា តែ តំណាង អាជ្ញាធរ បារាំងសែស គេ បដិសេធ គ្មាន ឱ្យ ហេតុផល ពិតប្រាកដ មិន តែ ប៉ុណ្ណោះ មិនទាំង យក តារាងនោះ មកមើលផង ហើយ គេ សម្រេច ដោយ អំណាច យក សម្តេច សីហនុ ជាព្រះមហាក្សត្រ បន្តរាជ្យ ពីព្រះអយ្យកោរបស់ព្រះអង្គ។ គេលើក ហេតុផល ថា សម្តេច សីហនុ មាន បិតា ជា វង្ស នរោត្តម និង មាតា ជា វង្ស ស៊ីសុវត្ថិ ដូច្នេះ វា អាចនឹង

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

សង្រួបសង្រួម វង្ស ទាំងពីរ ទៅ អនាគត កុំឱ្យ មាន ទំនាស់នឹង គ្នា។ វង្ស ស៊ីសុវត្ថ មាន ព្រះមហាក្សត្រ ពីរអង្គ រួចមកហើយ ដូច្នេះ ត្រូវ វេន វង្ស នរោត្តម ម្តង ដែល ជា បុត្រា នៃ វង្ស ទាំងពីរផង។ ហេតុផលនោះ វា គ្មានទំនងអ្វីនោះឡើយ តែដោយសារ បារាំង នៃ របប Vichy គេ មាន អំណាច លើខ្មែរ ហើយ គេ ត្រូវការ ព្រះមហាក្សត្រខ្មែរ ដែល ជា យុវស្តេច ដើម្បី គេ ស្រួល ដឹកនាំ តាមចិត្ត ដែល គេចង់បាន តែប៉ុណ្ណោះ។ គេ អាច សួរ ជា សំនួរ ដែរ ថា តើ ទ្រង់ សិរិមតៈ ឆ្លៀត ឱកាស ដើម្បី សងសឹង សម្តេច សីហនុ ពី រឿង អតីតកាល ? ឬ ដំណួល នៃ សម្តេច សីហនុ វា នឹងមាន លទ្ធភាព អាច រៀបចំឡើងវិញ នូវ របប រាជានិយម ពិតប្រាកដ ដែលមាន ព្រះមហាក្សត្រ ពិតប្រាកដ ? បំណងនេះ វា ប្រហែល អាច មាន នៅក្នុង អារម្មណ៍ របស់ ទ្រង់ សិរិមតៈ ព្រោះ ទ្រង់ ជា ស្តេច, តែ ទ្រង់ ជា មនុស្សឆ្លាតម្នាក់ ដូច្នេះ ទ្រង់ ច្បាស់ជា មិនឱ្យ អារម្មណ៍នេះ បំពេរទ្រង់បាននោះ ឡើយ នៅក្នុង បរិបទ និង បរិស្ថាន នយោបាយ នៅពេលនោះ ព្រោះ ទ្រង់ ដឹងច្បាស់ ថា នៅក្នុង មជ្ឈដ្ឋាន នៃ អ្នកអបអម លោក លន់ នល់ មាន ពួក អ្នកប្រឆាំង នឹង រាជានិយម, ដូច្នេះ វា គ្មាន ប្រយោជន៍អ្វី នឹង បង្កើត ទំនាស់នឹង អ្នកទាំងនោះ ដែល វា នាំរំខាន ដល់ គោលបំណង ចម្បង គឺ រំលំ សម្តេច សីហនុ ដើម្បី សង្គ្រោះ ប្រជាជាតិ ពុំមែន សង្គ្រោះ របប រាជានិយម នោះឡើយ។ តែ ទោះបី ទ្រង់ សិរិមតៈ ចង់ ឬ មិនចង់, កើត ជា ស្តេច វា នាំបង្កើតឯងៗ នូវ សត្រូវ វណ្ណៈ នៃ ចរន្ត ប្រវត្តិសាស្ត្រ

«រាស្ត្រ នឹង ស្តេច»។ ទ្រង់ សិរិមតៈ ដឹងខ្លួន អំពី អត្ថភាព អវិជ្ជមាននេះ, ដូច្នេះ ទ្រង់ ព្យាយាម តាមដែល អាចធ្វើទៅបាន ដើម្បី ជៀសវាង កុំឱ្យ ធ្លាក់ ទៅក្នុង ឧបាយកល របស់ សត្រូវ វណ្ណៈ ព្រោះ រឿងនេះ វា មិនអាស្រ័យ លើ ទ្រង់ តែ ម្នាក់ឯង នោះឡើយ។ គួរ ទទួល ស្គាល់ ថា លោក លន់ នល់ គាត់ ជួយ ទ្រង់ សិរិមតៈ ទាំង កម្លាំងចិត្ត និង កម្លាំងនយោបាយ ដើម្បី បន្ថយ ការវាយប្រហារ ពី សំណាក់ សត្រូវ វណ្ណៈ ដល់ ទ្រង់ នៅក្នុង បញ្ហា ទំនាស់ នេះ ដែល មាន អ្នកបង្កទំនាស់ គឺ ប្អូន បង្កើត របស់លោក, លន់ ណុល, និង ក្រុម លោក ហង្ស ធុនហាក់ ដែល មាន កេរ៍ឈ្មោះ ជា អ្នកសាធារណរដ្ឋ។ ត្រូវដឹងថា តាំង ពីដើមទីមកម្លេះ វា មាន សម្ព័ន្ធភាព ដោយ ផលប្រយោជន៍ រវាង «ហង្ស ធុន ហាក់-លន់ ណុល-កេង វ៉ាន់ សាក់» ដើម្បី ប្រឆាំងនឹង សិរិមតៈ ដើម្បី រំលំ រាជានិយម។ ហង្ស ធុន ហាក់ ជា អវតា នៃ កម្លាំង នយោបាយ, លន់ ណុល ជា កម្លាំង បាយ និង កេង វ៉ាន់ សាក់ ជា កម្លាំង មនោគមវិជ្ជា។

### ហេតុអ្វី បាន ជា ទ្រង់ សិរិមតៈ ជា សត្រូវ នឹង សីហនុ ?

តាំងតែ ពី ឆ្នាំ ១៩៤៦ មក ទ្រង់ សិរិមតៈ តែងតែ ធ្វើសហការ គ្មាន ក្រហែង ជាមួយនឹង សម្តេច សីហនុ។ ជា សហការ ដើម្បី ផលប្រយោជន៍ វណ្ណៈក្សត្រ, នយោបាយ និង ជាតិ។ គោលជំហរ សំខាន់ៗ របស់ សិរិមតៈ គឺ ទាមទារ ឯករាជ្យជាតិ ពី បារាំង, ស្ថា

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

បនា ស្ថិរ[16] នៃ របបដឹកនាំជាតិ ដើម្បី ផលប្រយោជន៍ជាតិ និង ធ្វើឱ្យប្រសើរឡើងវិញ នូវ សក្តិយស នៃ រាជានិយមខ្មែរ។ របត់ នៃ ព្រឹត្តិការណ៍ សំខាន់ៗ ដែល នាំឱ្យ ទ្រង់ សិរិមតៈ មាន ការ មិនទុកចិត្ត សម្តេច សីហនុ ហើយ ដកខ្លួន ចេញពី ជីវិត នយោបាយ ដោយ មិនចង់ ឱ្យមាន ទំនាស់នឹង ព្រះអង្គ៖

## ក្នុង វិស័យ រាជានិយម

នៅថ្ងៃ ទី៣ មេសា ឆ្នាំ ១៩៦០ ព្រះមហាក្សត្រ សុរាម្រិត ចូលទីវង្គត, តាម ច្បាប់ ធម្មនុញ្ញ ក្រុមប្រឹក្សា ព្រះរាជបល្លង្ក ត្រូវ ប្រជុំ ដើម្បី ជ្រើសរើស ជា បន្ទាន់ ព្រះមហាក្សត្រ បន្ត រាជ្យ។ ប៉ុន្តែ នៅ ពេលនោះ សម្តេច សីហនុ, ព្រះអង្គ កំពុង មាន អំណាចណាស់ ក្នុង ឋានៈ ព្រះអង្គ ជា ប្រធាន ចលនា សង្គមរាស្ត្រនិយម ដែល ជា ចលនា កាន់អំណាច ទាំង នីតិ បញ្ញាតិ និង នីតិ ប្រតិបត្តិ តែម្នាក់ឯង, ព្រះអង្គ ដោយ មិនចង់ឱ្យមាន ព្រះមហាក្សត្រថ្មី ក្រៅពីព្រះអង្គ ដោយសារ ព្រះអង្គ នៅពេល ដាក់រាជ្យ ថ្វាយ ព្រះបិតា បាន សប្បថស្បែ ថា ព្រះអង្គ មិនវិល ត្រឡប់ មក គ្រង រាជ្យសម្បត្តិ វិញឡើយ ដូច្នេះ ព្រះអង្គ ប្រើ អំណាច បង្គាប់ ឱ្យ រដ្ឋសភា កែ រដ្ឋធម្មនុញ្ញ បង្កើត ក្រុមប្រឹក្សា រាជានុសិទ្ធិ ហើយ តែងតាំង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ជា ប្រធាន បន្ទាប់ មក នៅថ្ងៃ ទី១៣ មិថុនា កែ រដ្ឋធម្មនុញ្ញ ជាថ្មី ម្តងទៀត ដើម្បី បង្កើត ស្ថាប័ន «ប្រមុខរដ្ឋ» ដែល មាន ព្រះអង្គ ជា ព្រះប្រមុខ

---

[16] ស្ថិរ គុៈ បិតថេរ, មាំមួន, ខ្ជាប់ខ្ជួន។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

អស់មួយជីវិត។ ទង្វើនេះ គឺ ព្រះអង្គ ព្បួរចោល ស្ថាប័ន ព្រះមហាក្សត្រ គឺថា ទុក ព្រះរាជបល្លង្ក ឱ្យនៅទំនេរ ហើយ គ្រាន់តែថ្វាយ ពុទ្ធសិទ្ធិ នៃ ព្រះមហាក្សត្រ ដល់ ព្រះមាតា។ របៀបធ្វើនេះ គឺ ជាការបំពាន ជាក់ស្ដែង លើ ច្បាប់ ធម្មនុញ្ញផង និង រាជប្រពៃណីផង ដោយ យក «អំណាចអញ» មក អនុវត្ត។ ទ្រង់ សិរិមតៈ ដែល ជា ស្ដេចមួយអង្គ មើលឃើញ ទង្វើនោះ ជា ការបន្ថោក ស្ថាប័ន ព្រះមហាក្សត្រខ្មែរ។ ចំពោះ ទ្រង់, សម្ដេច សីហនុ គួរតែ កំណែទំរង់ ច្បាប់ «ឧត្ត[17]រាជ្យសម្បត្តិ» ដែល អាណានិគមនិយមបារាំង គេ បកប្រែ មិនត្រឹមត្រូវ ថា រាជានិយមខ្មែរ ជា «រាជានិយម ជ្រើសតាំង» ព្រោះ គេ ស្រួលតែងតាំង ព្រះមហាក្សត្រខ្មែរ សំរាប់ បំរើ ផលប្រយោជន៏ របស់គេ[18]។ ការកែទំរង់ គឺ ផ្ដល់សិទ្ធិ ពេញច្បាប់ ឱ្យ ព្រះមហាក្សត្រ តែងតាំង «ព្រះទាយា» ជាផ្លូវការ ដើម្បី ឱ្យ ព្រះទាយានោះ ទទួលបាន នូវ ការអប់រំ ពីកុមារភាព ឱ្យស្គាល់ «ករណីយកិច្ច - កាតព្វកិច្ច - សិទ្ធិ» ច្បាស់លាស់ របស់ ព្រះមហាក្សត្រ ដ្បិត តំណែង ព្រះមហាក្សត្រ មិនមែន ជា តំណែង ដោយ ចៃដន្យ នោះឡើយ, វា ត្រូវមានគ្រោងទុក ពិប្រាកដ និង ត្រឹមត្រូវ ទៅ តាម ច្បាប់ រាជប្រពៃណី

[17] ឧត្ត : ដំណើរបន្តគ្នាមិនដាច់។

[18] នៅក្នុង សៀវភៅ លោក G. CŒDÈS – Les états hindouisés d'Indochine et d'Indonésie - លោក សរសេរថា នៅស្រុកខ្មែរ តាំងពីសម័យបុរាណមក មកដល់ សព្វថ្ងៃ ការឡើង គ្រងរាជសម្បត្តិ បន្ត ពីហ្លួង ចូលទីវង្គត តែងតែ បុត្រាច្បង របស់ព្រះអង្គ ដែល ជា ព្រះទាយាទ តែងតាំង។ មាន តែ ១៤ ករណី តែ ប៉ុណ្ណោះ ដែល វា កើតឡើង ខុសពី រាជប្រពៃណីនោះ។

# លង់ លល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

សហស្សវត្ស ដែល មាន ក្នុង ព្រះរាជាណាចក្រខ្មែរ តាំងពី បុរាណកាលមក។ តែ ចំពោះ ទ្រង់ សិរិមតៈ ទ្រង់ មិនជំទាស់នឹង របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ នោះទេ ព្រោះ អ្នកដឹកនាំជាតិត្រូវ មាន ការទទួលខុសត្រូវ ចំពោះមុខ ប្រជាពលរដ្ឋ ឬ ស្ថាប័នតំណាង ប្រជាពលរដ្ឋ ដែល មាន ប្រជាពលរដ្ឋ ជា អធិបតី គឺម្ចាស់ នៃ អំណាច ដែល មាន ចែង នៅក្នុង រដ្ឋធម្មនុញ្ញ ដូច្នេះព្រះជាពលរដ្ឋ មាន អំណាច ធម្មនុញ្ញ អាចប្តូរ អ្នកដឹកនាំបាន។ រីឯ ព្រះមហាក្សត្រ វិញ ព្រះអង្គ ជា តំណាង ចិរកាល នៃ ប្រជាជាតិ គឺ ការរួបរួមជាតិ, ឯកភាពជាតិ និង អធិបតេយ្យជាតិ។ ជាការពិត ទង្វើ របស់ សម្តេច សីហនុ ពាក់ព័ន្ធនឹង រាជានិយម វា ផ្ទុយស្រឡះ ពី ទស្សនៈ របស់ ទ្រង់ សិរិមតៈ ដែល វា នាំ បង្កើត អធិករណ៍ សម្ងំ នោះឯង។

## ក្នុង វិស័យ នយោបាយជាតិ

អធិករណ៍ សម្ងំនេះ វា បន្ទំ ជា រៀងរាល់ថ្ងៃ នៅក្នុង អារម្មណ៍ របស់ទ្រង់ សិរិមតៈ ដែលនាំឱ្យ ទ្រង់ ថប់ចិត្ត ក៏សុខចិត្ត ទទួល តំណែង ជា អគ្គរាជទូត ប្រចាំនៅ សាធារណរដ្ឋចិន ប្រជាមានិត ពី ឆ្នាំ ១៩៦២ ដល់ ៦៤ បន្ទាប់មក នៅ ប្រទេស ជប៉ុន ពី ឆ្នាំ ១៩៦៦ ដល់ ១៩៦៧។ តំណែង នៅក្រៅ ប្រទេសនោះ វា អាច ឱ្យទ្រង់ នៅឆ្ងាយ ពី សម្តេច សីហនុ ដែល ទ្រង់ ទុក ជា ហេតុ នៃ ការធុញថប់ របស់ទ្រង់។ តែ ក្នុង រយៈពេល ប្រាំឆ្នាំ នៅបរទេស, ទ្រង់សិរិមតៈ តាមដានជានិច្ច នយោបាយ ក្នុងប្រទេស។ កាប្តូរ

នយោបាយ សេដ្ឋកិច្ច របស់ សម្ដេច សីហនុ ពី សេដ្ឋកិច្ចសេរី ទៅ សេដ្ឋកិច្ចសង្គមនិយម បន្ទាប់ ពី បាន បញ្ឈប់ ទំនាក់ ទំនង ផ្លូវទូត ជា មួយ សហរដ្ឋអាមេរិក វា ពុំមាន លទ្ធផល ដូច ដែលចង់បាន។ ជំនួយ សេដ្ឋកិច្ចចិន ដែល សម្ដេច សីហនុ ប្រកាស ថា វា អាច ផាត់ទាត់នឹង ជំនួយ អាមេរិកាំង វា គ្រាន់ តែមាន លក្ខណៈ ជា និមិត្តរូប នៃ ការប្រឆាំងនឹង ចក្រពត្រ អាមេរិកាំង តែគ្មាន ប្រសិទ្ធិភាពនោះឡើយ។ ជា ពិសេស សេដ្ឋកិច្ច សង្គមនិយម តាម គំរូ ចិន វា មិនអាច ទាក់ទាញ មូលធន បរទេស សំរាប់ ធ្វើ អភិវឌ្ឍន៍។ បន្តៗមក ស្រុកខ្មែរ ជួបប្រទះ នឹង វិបត្តិ សេដ្ឋកិច្ចជ្រៅ។ រដ្ឋខ្មែរ ស្ថិត នៅក្នុង ភាពទ្បងចុង រហូត ដល់ ទៅ គ្មាន ថវិកា សំរាប់ បង់បៀវត្ស ដល់ ពួក អ្នករាជការ ស៊ីវិល និង យោធា ហើយ ដើម្បី ដោះស្រាយ ជា បន្ទាន់ នូវ បញ្ហានោះ សម្ដេច សីហនុ អនុញ្ញាត ឱ្យ បើក កាស៊ីណូ នៅ ទីក្រុង ភ្នំពេញ និង កំពង់សោម ដើម្បី យក ព័ន្ធ សំរាប់ បើក ប្រាក់ខែ ឱ្យ ពួក អ្នករាជការ។ វិធានការនោះ វា ប៉ះពាល់ផ្ទាល់ ដល់ សីលធម៌ របស់ ប្រជាពលរដ្ឋ ដែល ជា អ្នកកាន់ព្រះពុទ្ធ សាសនា ដែលនាំឱ្យ សហជម្ទិក ពុទ្ធសាសនា (clerc bouddhique) មាន ការស្រពន់ចិត្ត ក្រៃលែង។ ក្រោយមក សម្ដេច សីហនុ ព្រះអង្គ ទទួលស្គាល់ ជា សាធារណៈ កំហុស របស់ព្រះអង្គ ហើយ ព្រះអង្គ ទូលបន្ថែម ថា បើ ព្រះអង្គ អាចវិលត្រឡប់មកក្រោយវិញ គឺ ច្បាស់ ជា ព្រះអង្គ មិនបោះបង់ ជំនួយ សេដ្ឋកិច្ច សហរដ្ឋអាមេរិក ជា ដាច់ខាត ដែល វា នាំ បង្កើត វិបត្តិ ដល់ ជាតិ និង រូប

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ព្រះអង្គផ្ទាល់។ ជាការពិត អ្វី ដែល សម្តេច ប្រព្រឹត្ត ដោយ ភាន់ច្រឡំក្តី ដោយ ចេតនាក្តី វា នាំឱ្យទ្រង់ សិរិមតៈ ខ្មាំង[19] នៅក្នុងចិត្ត លើ សមត្ថភាព របស់សម្តេច សីហនុ បន្ត ដឹកនាំ ប្រជាជាតិ នោះឯង។

## ក្នុង វិស័យ នយោបាយអន្តរជាតិ

ក៏ប៉ុន្តែ ការទទួល កំហុស របស់ព្រះអង្គ មិនរំខាន ដល់ ព្រះអង្គ បន្ត ទំនាក់ទំនង ពិសេស ជាមួយ ចិន និង យួន កុម្មុយនិស្ត ដូចយ៉ាង នៅខែ មីនា ឆ្នាំ ១៩៦៥ ព្រះអង្គ ទទួល ធ្វើ នៅ ភ្នំពេញ សន្និសិទ្ធ នៃ ប្រជាជន ឥណ្ឌូចិន ដែល មាន ប្រទេស យួនខាងជើង (យួនកុម្មុយនិស្ត), ចិន ប្រជាមានិត, រដ្ឋាភិបាល ប្រថេតលាវ (លាវ កុម្មុយនិស្ត) និង រដ្ឋាភិបាល យៀកកុង។ សន្និសិទ្ធនោះ ជា ការបង្កហេតុ បន្ថែម ចំពោះ សហរដ្ឋអាមេរិក ដែល បណ្តាល ឱ្យមាន ការបញ្ឈប់ ទំនាក់ទំនងទូត រវាង ប្រទេស ទាំងពីរ។ នៅ រយៈពេលនោះ ទ្រង់ សិរិមតៈ ទ្រង់ ជា អគ្គរាជទូតខ្មែរ នៅ សាធារណរដ្ឋចិន ប្រជាមានិត ដូច្នេះ ទ្រង់ ឃើញនឹងភ្នែក គ្រប់ ទំនាក់ទំនង សម្តេច សីហនុ នឹង ចិន ដែល ជា អន្ត្រត របស់ព្រះអង្គ រុញ ស្រុកខ្មែរ ឱ្យធ្លាក់ ទៅក្នុង អន្លង់ មរណា របស់ ចិន និង យួនកុម្មុយនិស្ត។ នៅឆ្នាំ ១៩៦៧ ក្រោយពី បញ្ចប់ បេសកកម្ម ទូត នៅ ប្រទេស ជប៉ុន, ទ្រង់ សិរិមតៈ វិលត្រឡប់ចូល ស្រុកខ្មែរ វិញ ហើយ បន្ត សង្កេត វិ

[19] ខ្មាំង : សង្ស័យ។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

នាដកម្ម ដែល ប្រជាពលរដ្ឋខ្មែរ កំពុង រងគ្រោះ ពី ការដឹកនាំ ជាតិ របស់សម្តេច សីហនុ។ នៅពេល សមាជ ពិសេស នៅឆ្នាំ ១៩៦៩, នាម ទ្រង់ សិរិមតៈ ត្រូវបាន គេ បញ្ចូល នៅក្នុង តារាង នៃ គស្សរជន ១០ នាក់ សំរាប់ ថ្វាយ សម្តេច សីហនុ រើសសម្រាំង ជា នាយករដ្ឋមន្រ្តី ដើម្បី រៀបចំ បង្កើត រាជរដ្ឋាភិបាល ស្រោច ស្រង់ជាតិ។

វិស័យ ទាំងបី ដែល បានរៀបរាប់ ខាងលើនេះ វា ជា គោលជំហរ របស់ទ្រង់ សិរិមតៈ ដែល នាំឱ្យមាន ទំនាស់ ជាមួយ សម្តេច សីហនុ នៅពេល ដែល ទ្រង់ ចូលរួម ជា សមាជិក នៃ រាជរដ្ឋាភិ បាល ស្រោចស្រង់ជាតិ ដឹកនាំដោយ លោក លន់ នល់។

## គោលជំហរ របស់លោក លន់ នល់

លោក លន់ នល់ ជា អ្នករាជានិយម គ្មាន លក្ខខណ្ឌ ជា វង្ស ត្រកូល បំរើ ព្រះមហាក្សត្រ តពូជ ហើយ ខ្លួនលោកផ្ទាល់ ជា អ្នកបំរើ ជំនិញម្នាក់ របស់សម្តេច សីហនុ គ្មានក្រហែង។ នៅ ក្នុង លក្ខណៈ ស្មោះត្រង់នោះឯង ដែល សម្តេច សីហនុ តែងតាំងលោក លន់ នល់ ជា អគ្គនាយសេនាធិការ និង អគ្គ មេបញ្ជាការ កងទ័ពខេមរភូមិន្ទ អស់រយៈពេល ដ៏យូរបំផុត ទោះបី លោក មិនមែន ជា នាយទាហាន អាជីព។ ស្ទើរគ្រប់ រាជ រដ្ឋាភិបាល, នាយករដ្ឋមន្រ្តី តែង ជ្រើសយកលោក ជា រដ្ឋមន្រ្តី ក្រសួងការពារជាតិ សំរាប់ បំពេញចិត្ត សម្តេច សីហនុ។ ដូច្នេះ វា មាន សហចិត្ត រវាង សម្តេច សីហនុ ជាមួយ លោក លន់ នល់

ដែល គ្មាន អ្នកណាម្នាក់ អាច សង្ស័យ ថា លោក លន់ លន់ នឹង អាចក្បត់ សម្តេចបាន។ ត្រូវដឹងថា រហូត មកដល់ ថ្ងៃ ទី១៦ មីនា ឆ្នាំ ១៩៧០, លោក លន់ នល់ គ្មានគោលបំណង ទំលាក់ សម្តេច សីហនុ ពី មុខដំណែងនោះឡើយ។ សួរថា ចុះហេតុអ្វី បាន ជាលោក ប្តូរចិត្ត ? កត្តា មួយចំនួន មាន ដូច ខាងក្រោមនេះ។

### ការបដិសេធ របស់សម្តេច សីហនុ ទទួលស្តាប់ ប្រតិភូ របស់ព្រះមហាក្សត្រីយានី

បន្ទាប់ ពី មាន កើត បាតុកម្ម នៃ ប្រជាកសិករ នៅ ខេត្ត ស្វាយរៀង នៅថ្ងៃ ទី៨ មីនា ឆ្នាំ ១៩៧០ ប្រឆាំងនឹង វត្តមាន កងទ័ពយៀកកុង នៅ ស្រុកខ្មែរ និង បាតុកម្ម អ្នកភ្នំពេញ នៅថ្ងៃ ទី១១ មីនា សូមឱ្យ រដ្ឋសភា ដោះស្រាយ ជាបន្ទាន់ អំពី បញ្ហា នៃ ការតាំងទីទ័ព យួនកុម្មុនិស្ត នៅលើ ទឹកដីខ្មែរ ដែល វា នាំឱ្យមាន ការវាយកំទិច ស្ថានទូត យួនខាងជើង និង យៀកកុង, លោក លន់ នល់ សូមចូលគាល់ភ្លាម ព្រះមហាក្សត្រីយានី ដែល ជា មាតា របស់សម្តេច សីហនុ។ ប្រតិកម្ម របស់ព្រះអង្គ គឺ សូមឱ្យលោក លន់ នល់ តែងតាំង ប្រតិភូមួយ[20] ដឹកនាំ ដោយ ទ្រង់ កន្ទុល ដើម្បី ចូលគាល់ សម្តេច សីហនុ គង់ នៅ ស្រុកបារាំង ធ្វើសេចក្តីរាយការណ៍ ពី ស្ថានការណ៍ពិត ដែល កំពុងកើតនៅ ស្រុកខ្មែរ ថ្វាយព្រះអង្គ។ ព្រះមហាក្សត្រីយានី បានផ្ញើរ ទូរលេខ ថ្វាយដំណឹង ដល់ ព្រះរាជបុត្រ តែ សម្តេច

[20] ប្រតិភូនោះ មាន ទ្រង់ កន្ទុល ជា អ្នកដឹកនាំ និង សមាជិក ពីររូប គឺ លោក យ៉ែម សំបួរ និង ឧប គឹម អាង។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ឆ្លើយតប មក ព្រះរាជមាតា ថា ព្រះអង្គ មិនព្រម ទទួល ប្រតិភូ នោះ ឱ្យចូលគាល់ ហើយថែម បញ្ជាក់ តាម ទូរលេខ ទី២ ថ្វាយ ចំពោះ ព្រះមាតា ថា ព្រះអង្គ ប្រឆាំងនឹង អំពើ ដែល កំពុង កើតមានឡើង នៅ ស្រុកខ្មែរ ដោយ ចោទប្រកាន់ ត្រង់តែម្តង ថាជា ឧបាយកល របស់ពួក អ្នកស្តាំនិយម ប្រឆាំងនឹង នយោបាយ របស់ព្រះអង្គ។ ដូច្នេះ ការផ្តាច់ ទំនាក់ទំនង រវាង លោក លន់ នល់, រាជរដ្ឋាភិបាល និង ព្រះមហាក្សត្រីយានី ជាមួយ សម្តេច សីហនុ វា ជា ឆន្ទៈ របស់សម្តេច សីហនុ។ ការណ៍ នេះ ព្រះអង្គ មាន ជំនឿថា ព្រះអង្គ នឹងដោះស្រាយ ជា មួយ សហភាពសូវៀតផ្ទាល់ ព្រោះ នឹងយាងចេញ ពី ប្រទេសបារាំង ទៅធ្វើ ទស្សនកិច្ច នៅប្រទេសនោះ ព្រោះ រដ្ឋាភិបាល របស់គេ មាន ឥទ្ធិពលច្រើន ទៅលើយួនកុម្មុយនិស្ត។ ក៏ប៉ុន្តែមាន ពាក្យ ចចាមអារ៉ាម ថា សម្តេច នឹងយាងត្រឡប់មកស្រុកខ្មែរវិញ នៅ ថ្ងៃ ទី១៦ មីនា, ថា មាន មន្ត្រីទូតខ្មែរម្នាក់[21] នៅ ស្រុក បារាំង បានថតខ្សែអាត់ សម្លេង សម្តេច សីហនុ ហើយផ្ញើមក ទ្រង់ សិរិមតៈ នៅក្នុងសម្លេងនោះ គឺថា សម្តេច សីហនុ មាន ព្រះបន្ទូល ថា នៅពេលព្រះអង្គ យាង មកដល់ ស្រុកខ្មែរ វិញ ព្រះ អង្គ នឹងបញ្ជា ឱ្យយក ពួក ជនក្បត់នឹង ព្រះអង្គ ទៅ ប្រហារ ជីវិត, ថា ប្រសិន ជា សម្តេច សីហនុ យាង មក ស្រុកខ្មែរ តាម យន្តហោះ លោក លន់ នល់ នឹងបញ្ជា ឱ្យយន្តហោះ ទ័ពអាកាស

[21] មន្ត្រីទូតនោះ គឺ ទ្រង់ ស៊ីសុវត្ថិ ឥស្សរោ ដែល ត្រូវជា អនុជ ទ្រង់ សិរិមតៈ។

# លន់ នល់ - សិរិមតះ : សត្រូវ ឬ មិត្ត ?

ខ្មែរ បាច់កំទិច យន្តហោះ របស់ព្រះអង្គ។ ពិត ឬ ពិត ពាក្យ ចចាមអារ៉ាម ទាំងនោះ វា មាន នៅក្នុង គំនិត រៀងខ្លួន នៃ ភាគីទំនាស់ ទាំងពីរនោះ ព្រោះ វា ជា ការប្រុងប្រយត្ន ជា ធម្ម ជាតិ សំរាប់ ការពារខ្លួន រៀងៗខ្លួន។ តើ នៅពេលនោះ អ្នកណា អាច ទុកចិត្ត អ្នកណាបាន ព្រោះ វា ជា រឿង អាយុជីវិត។ ខាង សម្តេច ព្រះអង្គ ត្រូវតែជឿ, ខាង លោក លន់ នល់ គាត់ ធ្លាប់ ស្គាល់ច្បាស់ កំហឹង គ្មាន ព្រំដែន របស់សម្តេច ព្រោះ វា មាន ឧទាហរណ៍ នៅ ត្រពាំងក្រឡឹង ដែល ជា អាឃាតនដ្ឋាន ពួក ខ្មែរសេរី តាម បញ្ជា របស់សម្តេច ព្រោះព្រះអង្គ ចោទ ជា ពួក ជនក្បត់ជាតិ។ តែទោះបីយ៉ាងណា ក៏ វា គ្មាន ផែនការ បាញ់កំ ទិច យន្តហោះនោះដែរ ព្រោះ វា មិនមែន ជា ចារិត របស់លោក លន់ នល់។

### កត្តាកងទ័ព

ដូចជំរាប ពីខាងលើរួចមកហើយ ទោះបី លោក លន់ នល់ មិន មែន ជា នាយទាហាន អាជីព តែ លោក បានសិក្សា មុខវិជ្ជា មួយចំនួន ជាមួយ នាយទាហានធំៗ បារាំង ដែល គេ មក បំពេញកិច្ច នៅក្នុង បេសកកម្ម អនុព័ន្ធ យោធា (attaché militaire) បារាំងសែស ក្រោយ ពី ស្រុកខ្មែរ ទទួល បាន ឯករាជ្យ បរិបូណ៌ ដូចជា វិជ្ជា នាយសេនាធិការ, មេបញ្ជាការ, យុទ្ធសាស្ត្រ, ត្រួតត្រា អន្តរកងទ័ព ។ល។ លោក ស៊ូស្តែន ហ្វែណង់ដែស, នាយទាហាន

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ខ្មែរម្នាក់ ដែល ជា អតីត សិស្ស « សាលា សង្គ្រាម » (école de guerre)[22] នៅ ប្រទេសបារាំង, ក៏ធ្លាប់ លោក លន់ នល់ ហៅរក ឱ្យជួយពន្យល់លោក អំពី វិជ្ជា យោធា ផងដែរ[23]។ មួយវិញទៀត លោក កាន់ តំណែង អគ្គនាយសេនាធិការ និង អគ្គមេបញ្ជាការ កងខេមរភូមិន្ទ យ៉ាងយូរបំផុត ដែល នាំឱ្យ លោក កសាង ទំនាក់ទំនង ជា មេទ័ព ដ៏ជាទីស្រឡាញ់ផង និង គោរពផង ពី សំណាក់ នាយទាហានខ្មែរ គ្រប់ថ្នាក់។ ពួក នាយទាហាន អាជីព ជាន់ខ្ពស់ អាចនឹង រិះគន់លោក លន់ នល់ ពី កង្វះខ្លះៗ នៅក្នុង មុខវិជ្ជាយោធា តែ ទាំងអស់គ្នា យល់ស្របគ្នា ថា គាត់ ជា មេទ័ព ដ៏ល្អម្នាក់ ប្រកបដោយ សីលធម៌ និង យុត្តិធម៌។ ការណ៍នេះ លោក លន់ នល់ គាត់ ដឹងច្បាស់ នៅក្នុងចិត្ត ថា នៅក្នុង កងទ័ព ប្រជាប្រិយភាព របស់គាត់ មិនចាញ់ សម្ដេច សីហនុ នោះឡើយ។ ដូច្នេះ លោក អាច ទុកចិត្ត លើ កងទ័ព ថា នឹងដើរតាមលោក នៅពេលណាមួយ ដែល លោក ត្រូវការវា ទោះបី ជា ផ្លូវ បញ្ច្រាស ពី ផ្លូវ របស់សម្ដេច សីហនុ។ តែ អារម្មណ៍នេះ មិនដែល ឱ្យលោក មាន គំនិត បន្តិចឡើយ ចង់ ក្បត់នឹងសម្ដេច ព្រោះ វា គ្មាន ផ្ដល់ ផលអ្វីផ្សេងទៀត លើសពីលោក មានរួចមកហើយ គឺថា នៅក្នុង កងទ័ព លោក មាន អំណាច គ្រប់គ្រាន់ វិ

---

[22] ដែល ជា សាលា ជាន់ខ្ពស់បំផុត នៃ កងទ័ព បារាំង។ នាយទាហានខ្មែរ មួយចំនួនតូច បាន ទៅ សិក្សា នៅក្នុង សាលានោះ។

[23] ជំនួយនេះឯង ដែល នាំឱ្យលោក ទាំងពីរ រាប់អាន ជិតស្និទ្ធនឹងគ្នា ដែល លោក លន់ នល់ មិន យំ លោក ស៊ូស្តែន ហ្វែណង់ដែស ដូច នាយទាហានជាន់ខ្ពស់ មួយចំនួនតូច ដែល ជា អ្នកជំនិតនឹង សម្ដេច សីហនុ។

# លង់ នល់ - សេរីមនះ : សត្រូវ ឬ មិត្ត ?

៦ នៅក្នុង ព្រះរាជាណាចក្រ លោក មាន កេរ៍ឈ្មោះ ជា សុជន[24] ផងនោះដែរ ហើយ លោក កើត នៅក្នុង វង្ស អ្នករាជានិយម ដែល ទុក របបនេះ ជា អាយុជីវិត នៃ ប្រជាជាតិខ្មែរ។

## ចិត្តពន្ធាខ ឬ ច្រើកល់ របស់សម្ដេច សីហនុ

ចាប់ ពី ឆ្នាំ ១៩៦៦ សម្ដេច សីហនុ បង្កើន ការទំនាក់ទំនង ជាមួយ ចិន និង យួន កុម្មុយនិស្ដ ដូចយ៉ាង នៅ ឆ្នាំ ១៩៦៨ ព្រះអង្គ តម្លើង ស្ថានតំណាងសេដ្ឋកិច្ច យួនខាងជើង ប្រចាំ នៅ ស្រុកខ្មែរ ជា ស្ថានទូត, ធ្វើការទំនាក់ទំនង ជាធម្មតា វិញ ជាមួយ ចិនប្រជាមានិត ក្រោយ ពី មាន ជម្លោះ អំពី រឿង បះបោរ ប្រជាកសិករ នៅ ភូមិ សំឡូត ក្នុង ខេត្ត បាត់ដំបង ហើយ នៅឆ្នាំនោះដែរ ព្រះអង្គ ស្វែងរក ការទំនាក់ទំនង ជា ថ្មី ជាមួយ សហរដ្ឋអាមេរិក បន្ទាប់ ពី ព្រះអង្គ អនុញ្ញាត ជា សម្ងាត់ ឱ្យ កងទ័ពអាកាស អាមេរិកាំង នៅ យៀកណាម ខាងត្បូង ទំលាក់ គ្រាប់បែក នៅ ស្រុកខ្មែរ លើ ទីតាំង កងទ័ពយៀកកុង។ តែ នៅថ្ងៃ ទី៩ ឧសភា ឆ្នាំ ១៩៦៩ ព្រះអង្គ តម្លើង ស្ថានដំណាង យៀកកុង ប្រចាំនៅ ស្រុកខ្មែរ ឱ្យឡើង ជា ស្ថានទូត ហើយ នៅ ថ្ងៃ ទី១១ មិថុនា ប្រកាស ការរៀបចំ នៃ ការទំនាក់ទំនងទូត ជាមួយ សហរដ្ឋអាមេរិក ឡើងវិញ, ប៉ុន្តែ បីថ្ងៃបន្ទាប់មក ព្រះអង្គ ប្រកាស ទទួលស្គាល់ យៀកុង ជា រដ្ឋាភិបាល បណ្ដោះអាសន្ន នៃ សាធារណរដ្ឋ យៀកណាម។ ហើយ នៅថ្ងៃ ទី២១ សីហា

---

[24] សុជន : ជន ប្រកបដោយសីលធម៌ និង សន្ដានទាន។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ព្រះអង្គ ទទួល លោក ព្រឹទ្ធសភា អាមេរិកាំង ឈ្មោះ Mike Mansfield មកធ្វើ ទស្សនាកិច្ចរដ្ឋ នៅ ស្រុកខ្មែរ។ នៅខែ ធ្នូ ព្រះអង្គ ព្យួរ បេសកកម្ម គណកម្មធិការ អន្តរជាតិ នៃ ការត្រួតពិនិត្យ វត្តមាន កងទ័ព បរទេស នៅ ស្រុកខ្មែរ ដែល សន្និសិទ្ទ នៅទី ក្រុងហ្សឺណែវ បានបង្កើតឡើង នៅឆ្នាំ ១៩៥៤ ដើម្បី ត្រួតពិនិត្យ ការដក កងទ័ពយួនកុម្មុនិស្ត និង បារាំង ចេញពីស្រុកខ្មែរ។

លោក លន់ នល់ សង្កេតឃើញ ចិត្តពង្វាង របស់សម្តេច សីហនុ ដែល គួរឱ្យបារម្ភ ទោះបីលោក ចូលរួម យ៉ាងសកម្ម ក្នុង ឋានៈ ជា រដ្ឋមន្ត្រី ការពារជាតិ, អគ្គនាយសេនាធិការ និង អគ្គមេបញ្ជាការ កងទ័ព ខេមរភូមិន្ទ។ ត្រូវដឹងថា ការចូលរួម មិនមានន័យ ថា លោក ចែករំលែង ១00% ការប្រើកល នៃ នយោបាយ អន្តរជាតិ របស់សម្តេច សីហនុ នោះឡើយ។ នៅពេលលោក ឡើងកាន់តំណែង ជា នាយករដ្ឋមន្ត្រី នៃ រដ្ឋាភិបាល ស្រោចស្រង់ជាតិ, បញ្ហា យៀកកុង ត្រូវបាន លើកឡើងពិគ្រោះ ជាមួយ សម្តេច សីហនុ, ប៉ុន្តែ ក្នុង វិស័យ នយោបាយ អន្តរជាតិ វា ជា បុព្វសិទ្ធិ ដាច់មុខ របស់ ព្រះប្រមុខរដ្ឋ ដែលមានឈ្មោះថា « នយោបាយ ជាន់ខ្ពស់ របស់ សម្តេចឳ », ដូច្នេះ ការពិគ្រោះនោះ វា គ្រាន់តែ មាន សភាព ជា ការថ្វាយដំណឹង ដល់ សម្តេច, ហើយ សម្តេច ប្រគល់ សំណុំរឿងខ្លះ ឱ្យ នាយករដ្ឋមន្ត្រី យកទៅពិនិត្យ។ នៅស្រុកបារាំង នៅខែ កុម្ភៈ ឆ្នាំ ១៩៧0, សម្តេច សីហនុ និង លោក លន់ នល់ បានជួបគ្នា, នៅក្នុងជំនួបនោះ សម្តេច សីហនុ បានលើកយក បញ្ហា វត្តមាន យួន

យៀកកុង នៅលើ ទឹកដីខ្មែរ មក និយាយដែរ តែគ្រាន់តែ ជាការពិពណ៌នា នៅក្នុង នយោបាយ ទូទៅ តែប៉ុណ្ណោះ, ចំណែកខាង លោក លន់ នល់, លោក ក៏មិនហ៊ាន យក បញ្ហានោះ មកចោទ ជា សំនួរដែរ ថា ត្រូវធ្វើយ៉ាងបែបណា ជា អាទិភាព ដ្បិតលោក ទុកជា « នយោបាយ ជាន់ខ្ពស់ របស់សម្តេច[25] »។

[25] គួរ លើកយក «នយោបាយ ជាន់ខ្ពស់ របស់សម្តេច» មកពិនិត្យ ជូនអ្នកអាន ឲជ្រាបដឹង ដែល មានកើតឡើង នៅក្នុងសម័យនោះ ដូចខាងក្រោមនេះ :
«លោក វរសេនីយឯកស៊ូស្តែន ហ្វែណង់ដែស កាលនោះ ជា រដ្ឋលេខាធិការក្រសួងសន្តិសុខជាតិ នៅក្នុង រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដឹកនាំដោយ លោក លន់ នល់ មានគំនិត ផ្ទាល់ របស់លោក ធ្វើអង្កេតអំពី ទីតាំង មូលដ្ឋានសឹក យួនកុម្មុយនិស្ត នៅក្នុងស្រុកខ្មែរ។ ក្រោយពីបានពត៌មានច្បាស់លាស់ រួចស្រេចអស់ហើយ លោកយក ឯកសារនេះទៅប្រាប់មិត្ត របស់លោក គឺ លោក វរសេនីយឯក អុំ ម៉ាណូរិន (លោកជា ប្អូន របស់អ្នកម្នាង មូនិច ដែល ជាស្នំឯក របស់ សម្តេចសីហនុ នៅជំនាន់នោះ) ពេលនោះ មានមុខដំណែង ជា រដ្ឋលេខាធិការក្រសួងការពារផ្ទៃដីក្នុងប្រទេស។ បានឯកសារនេះភ្លាម លោន អ៊ុម ម៉ានូរិនប្រញាប់ យកទៅ ថ្វាយ សម្តេច សីហនុ។ ក្រោយ ពី បាន ទតឃើញ ឯកសារនេះហើយ ព្រះអង្គ សួរទៅកាន់ លោក អ៊ុម ម៉ានូរិន ថា : តើ ស៊ូសស្តែន គេ យល់បែបណា ? លោក ម៉ានូរិន ឆ្លើយថា : ក្នុងស្ថានភាពបែបនេះ បើ ពួកយៀកកុង ចង់វាយ ស្រុកខ្មែរ គឺ គេអាច វាយយកបាន ក្នុងរយះពេលតែ ២៤ម៉ោង តែប៉ុណ្ណោះ។
ពីថ្ងៃក្រោយមក លោក ស៊ូស្តែន ហ្វែណង់ដែស បាន ត្រូវ លោក ឧត្តមសេនីយ ញ៉ឹក ជូឡុង នៅពេលនោះ មានមុខងារ ជា អគ្គមេបញ្ជាការជាន់ខ្ពស់ នៃ កងទ័ព ខេមរភូមិន្ទ កោះហៅ លោក ឲមកជួបលោក ជាប្រញាប់ នៅស្រុក យ៉ាក់លោម ក្នុង ខេត្តរតណៈគីរី។ តាមយន្តហោះ ពីភ្នំពេញ មក ខេត្តរតណៈគីរី លោក ហ្វែណង់ដែស មាន អារម្មណ៍រីករាយដោយ លោកយល់ ឃើញថា កិច្ចការ របស់លោក នាំ ប្រយោជន៍ ដល់ជាតិ បាន ជា អគ្គមេបញ្ជាការ អញ្ជើញលោក មកជួបដូច្នេះ ហើយស្មាដៃនេះប្រហែល អាចឲលោក អាចឡើង ឋានន្តរស័ក្តិ ពិសេស ជាឧត្តមសេនីយ ជាពុំខាន។ លោក បានមកដល់ យ៉ាក់ឡោម នៅម៉ោង ៩ យប់ ចូលជួប លោក ជូឡុង ជាបន្ទាន់។ លោក ជូឡុង ឃើញមុខ លោក

ដូច្នេះ នៅលើ ចំណុច រសើបនោះ វា បង្កើត ជា ទំនាស់ សម្ងំ រវាង សម្ដេច សីហនុ នឹង លោក លន់ នល់ ព្រោះ លន់ នល់ មិន សុភចិត្តនឹង (favorable) វត្តមាន កងទ័ពយៀកកុង នៅ ស្រុកខ្មែរ ដោយសារ លោក មាន ទំនាក់ទំនងផ្ទាល់ ក្នុង កិច្ចការរដ្ឋ និង យោធា ជាមួយ មេយៀកកុង នៅ ស្រុកខ្មែរ ហើយ លោក សង្កេតឃើញ ថា ពួកនោះ វា មាន ចារិត កញ្ឆ ឬ ព្រហើនណាស់ ជាមួយ មន្ត្រី និង នាយទាហានខ្មែរ[26]។ អ្វី ដែល វា មិនត្រូវនឹង ខ្មែរ នៅលើ ទឹកដីខ្មែរ វា តែងតែ និយាយ ថា ទៅ សួរ សីហនុ ទៅ ព្រោះ ពួកឯង គ្មានដឹងអ្វីទេ, រីឯ ជំនួយ ចិន ប្រជាមានិត នៅក្នុង វិស័យ កងទ័ព វិញ ច្រើនតែ ជា ការសន្យាទទេ និង ស្បិតរឹត។ ដូច្នេះ លោក លន់ នល់ ធ្វើសេចក្ដី សន្និដ្ឋាន នៅក្នុង

---

ស៊ូស្តែន ហ្វែណង់ដែស ភ្លាម និយាយយ៉ាង គំរោះ មកកាន់លោក ថា : ឯង ភ្លីភ្លើឬ ! បាន ជា ធ្វើអង្កេត រឿងយៀកកុង តើអ្នកណា ឲឯងធ្វើ ? ឯង មិនដឹងរឿងអស់នេះ ជា នយោបាយ ជាន់ខ្ពស់ របស់ សម្ដេច នោះទេ ? ឯង វិលត្រឡប់ ទៅភ្នំពេញវិញ ប្រមូល ឯកសាររឿងនេះ ដុត ចោល ទាំងអស់ ហើយ ឈប់និយាយរឿងនេះ ប្រាប់នរណាទៀត។ តាម យន្តហោះ វិលត្រឡប់មក រាជធានីវិញ លោក សូស្តែន ក្នុង អារម្មណ៍ របស់លោក លោក គ្មាន ការភិតភ័យ ពីទោសពៃ ដែល លោក អាចនឹង ទទួលនោះឡើយ តែ លោក គ្រាន់តែ មាន សេចក្ដីក្រៀមក្រំចិត្ត តែ ប៉ុណ្ណោះ នឹក អាណិត ដល់ស្រុក ដែលនឹង អាចជួបប្រទះ នូវគ្រោះថ្នាក់ ពីសំណាក់ យៀកកុង (Sic)»។ នៅស្រុកបារាំង លោក ឧត្តមសេនីយឯក ស៊ូស្តែន ហ្វែណង់ដែស តែងតែ និយាយ មផ្សំតផង ជា បញ្ឈឺវាសនាផង នៅពេលជួបជុំ ជាមួយ នាយទាហានខ្មែរ ទាំងឡាយ ដែល ជា ជនភៀស ខ្លួន។

[26] នៅក្នុង ជំនួប រវាង ប្រតិភូខ្មែរ ជាមួយ យួនខាងជើង និង យួនយៀក នៅថ្ងៃ ទី១៦ មីនា ឆ្នាំ ១៩៧០ ស្ដីពី ការសូមឱ្យដកទ័ពយួន ចេញពី ស្រុកខ្មែរ, ប្រតិភូយួន គេ ឆ្លើយ ថា សូមឱ្យលោក ទៅសួរ សម្ដេច សីហនុ សិន រឿងនេះ ពួកយើង មិននិយាយ ជាមួយ ពួកលោកទេ។

ចិត្ត ថា សម្ដេច សីហនុ កំពុង ចាញ់បោក ចិន និង យួនកុម្មុយនិស្ត ពិតប្រាកដ។

### កត្តា នៃ លោកសេរី

ការស្វែងរក នូវ ភាពនៅជិតគ្នា ឡើងវិញ រវាង ស្រុកខ្មែរ នឹង សហរដ្ឋអាមេរិក ដំបូងឡើយ វា ជា មន្ទប្រភា[27] នៃ សេចក្ដីសង្ឃឹម របស់លោក លន់ នល់ ថា សម្ដេច សីហនុ នឹងវិលត្រឡប់មករក ផ្លូវត្រូវវិញ សំរាប់ ស្រុកខ្មែរ។ ចំពោះលោក, សហរដ្ឋអាមេរិក គឺ ជា ការធានា ដ៏មាំមួន ដល់ អព្យាក្រឹតភាពខ្មែរ នៅក្នុងសង្គ្រាម នៅ យៀកណាម នៅចំពោះមុខ កងទ័ព យួនកុម្មុយនិស្ត។ មួយវិញទៀត អាមេរិកាំង គេ លែងជំទាស់នឹង អព្យាក្រឹតភាពខ្មែរ ទៀតហើយ តែ សូមឱ្យ តែ ខ្មែរ អនុវត្តវា ឱ្យម៉ត់ចត់ យោងតាម សម្ដី លោក Mike Mansfield ព្រឹទ្ធសភា អាមេរិកាំង។ នយោបាយ របស់លោក ប្រធានាធិបតី អាមេរិកាំង Nixon ដកទ័ព អាមេរិកាំង ចេញពីស្រុកយួន ត្រូវការ ឱ្យស្រុកខ្មែរ ប្រកាន់ អព្យាក្រឹតភាព របស់ខ្លួន គ្មានលំអៀង ទៅរក ចិន និង យួន កុម្មុយនិស្ត ជា ពិសេស ពួក យៀកកុង ដែល មកតាំងទី កងទ័ព នៅលើ ទឹកដីខ្មែរ។ សារនេះ ចំពោះលោក លន់ នល់, លោក យល់ឃើញ ថា វា ច្បាស់ ជា មាន ដំណោះស្រាយ តាម សន្តិវិធី នៃ សង្គ្រាម នៅ ស្រុកយួន ដែល មាន អាមេរិកាំង ជា អ្នកធានា នៃ អព្យាក្រឹតភាពខ្មែរ។ ដូច្នេះ កងទ័ព យួនកុម្មុយ

---

[27] មន្ទប្រភា : ពន្លឺព្រឹមៗ។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

និស្ត នឹងត្រូវ ដកខ្លួន ចេញពី ស្រុកខ្មែរ បើប្រសិនខ្លួន ចង់រក ដំណោះស្រាយ តាម សន្តិវិធី។ នយោបាយ នៃ ការរារែក (tergiversation) របស់សម្តេច សីហនុ វា គ្រាន់តែ ជា ការបន្ត នៃ អារម្មណ៍ មួយរយៈពេល តែ ប៉ុណ្ណោះ, ចង់ ឬ មិនចង់ ព្រះអង្គ នឹងធ្វើតាម អាមេរិកាំង ព្រោះ គោលការណ៍ នៃ នយោបាយ អន្តរជាតិ របស់ព្រះអង្គ គឺ « អព្យាក្រឹតភាពខ្មែរ »។

## កត្តាកំណត់រួម របស់លោក លន់ នល់ និង ទ្រង់ សិរិមតៈ

### អ្នករាជានិយម

ទ្រង់ សិរិមតៈ ជា ស្តេចមួយអង្គ ចំណែកលោក លន់ នល់ ជា អ្នករាជនិយម តត្រកូល ដែល នាំឱ្យ អ្នកទាំងពីរ មាន សាមានចិត្តនឹងគ្នា តាំងពី យុវអ្នករាជការ និង ដើម ជីវិតនយោបាយ នៅក្នុង បរិបទ នៃ ការរំដើបរំជួល របស់លោក សឺង ង៉ុកថាច់ ដែល មាន កេរ៍ឈ្មោះ ថា ជា អ្នកសាធាររដ្ឋ និង គណបក្សប្រជាធិបតេយ្យ ដែល មាន គោលការណ៍ បន្ថយ ឥទ្ធិពល ដល់ អតិបរមា នៃ រាជានិយម នៅក្នុង សង្គមខ្មែរ។ អ្នកទាំងពីរ រួមគ្នាបង្កើត គណបក្ស ខេមរប៉ុន្នការ ដែល មាន និន្នាការ រាជានិយម ដើម្បី ចូលរួមបោះឆ្នោត នៅឆ្នាំ ១៩៤៦ ជ្រើសរើសតំណាងរាស្ត្រ នៃ សភាជម្មនុញ, ប៉ុន្តែ មិនបាន ទទួលជោគជ័យនោះទេ ព្រោះ មិនបាន ទទួលបាន អាសនៈ។ បន្ទាប់មក អ្នកទាំងពីរ បែកគ្នា តែ ចូលបំរើផ្ទាល់ ហ្លួង សីហនុ នៅក្នុង រដ្ឋាភិបាល ដឹកនាំដោយ ហ្លួង សីហនុ, ក្នុងជួរ កងទ័ព និង ព្រះរាជបូ

ជនីយកិច្ច ដើម្បី ទាមទារ ឯករាជ្យ បរិបូរណ៍ ពី បារាំង។ ជា អ្នករាជានិយម, អ្នកទាំងពីរ មាន វិសមានចិត្ត នឹងលោក សឺង ង៉ុកថាញ់, ពួក អ្នកប្រជាធិតី ឆ្វេងនិយម និង ពួក អ្នកកុម្មុយនិស្ត។

## អ្នកជាតិនិយម

នៅក្នុង គោលការណ៍ កសាងឡើងវិញ សក្តិយស នៃ ប្រជាជាតិខ្មែរ ដែល បាត់បង់ តាំង ពី សតវត្ស ទី១៥ មក រហូត ធ្លាក់ចុះជា ប្រទេស ចំណុះ ឬ ខ្ញុំ សៀម, យួន និង បារាំង។ ការពារ ផលប្រយោជន៍ជាតិ នៅចំពោះមុខ ឥទ្ធិពល បរទេស, ការពារ ពុទ្ធសាសនា និង ទំនុកបម្រុង ឱ្យបាន ថ្កុំថ្កើង។

## អ្នកប្រជាធិបតីសេរី

អ្នកទាំងពីរ ទោះបី ជា អ្នករាជានិយម តែ មាន ការយល់ព្រមគ្មានការកក់ ឬ គ្មានលាក់លៀម នឹង លទ្ធិប្រជាធិបតេយ្យ និងរបប រាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។ នៅក្នុង គោលការណ៍នេះឯង ដែល អ្នកទាំពីរ ប្រឆាំងនឹង ចលនា ខ្មែរឥស្សរៈ, ខ្មែរសេរី និង ខ្មែរក្រហម ដែល ជ្រើសរើស ការតស៊ូ អាវុធ ជាមធ្យោបាយ ដោះស្រាយ ជម្លោះនយោបាយ។ នៅក្នុង គោលជំហរ នេះផង ដែល អ្នកទាំងពីរ បង្កើត គណបក្ស នយោបាយចូលរួម ការបោះឆ្នោត។ ការជ្រើសរើស លទ្ធិប្រជាធិបតេយ្យសេរីវា ជា ទំនាស់ ជា គោលការណ៍ នឹង ចលនា សង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ ដែល ជំរុញ អ្នកទាំងពីរ ឱ្យបោះបង់

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

សកម្មភាព នយោបាយ សុទ្ធសាធ ដោយ មិនចង់ឱ្យមាន ទំនាស់នឹងសម្តេច សីហនុ។ អ្នកទាំងពីរ រំលាយ គណបក្ស ខេមរ ប៉ុន្និការ ហើយ នាំគ្នា ជ្រើសរើស មុខងារ អ្នករាជការ ដើម្បី បំរើ ជាតិ។ លោក លន់ នល់ ជ្រើសយក កងទ័ព រីឯ ទ្រង់ សិរិមតៈ វិញ ទ្រង់ ជ្រើសយក មុខងារ នៃ អ្នករាជការ ស៊ីវិល។

កត្តាកំណត់រួម ដ៏ច្រើននោះឯង ដែល នាំឱ្យ អ្នកទាំងពីរ អាច មាន គោលជំហររួម នៅក្នុង ទំនាស់នឹង នយោបាយ របស់ស ម្តេច សីហនុ ហើយ មាន ជំនះឧបសគ្គ មួយចំនួន រវាងគ្នា នៅ ក្នុង អភិក្រម នៃ ការទម្លាក់ សម្តេច សីហនុ ពី មុខតំណែង។

## កត្តា នៃ គំនិតអសទិស រវាង លោក លន់ នល់ នឹង ទ្រង់ សិរិមតៈ

ការវិភាគ នៃ គំនិតអសទិស[28] រវាង លោកទាំងពីរ គឺ ធ្វើ នៅ ក្នុងតែ ក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០។ អ្វី ដែល នឹងមាន បន្ទាប់មកទៀត គឺ ក្រោយ ពី ទម្លាក់ សម្តេច សីហនុ និង ការបង្កើត សាធារណរដ្ឋខ្មែរ យើង មិនលើកយក វិភាគ នៅទីនេះទេ ព្រោះ វា ជា ប្រធានបទ សំខាន់ និង រីកសាយមួយ ដែល ត្រូវការ ធ្វើវិភាគ ដាច់ឡែក។

ទំនាស់ លោក លន់ នល់ និង ទ្រង់ សិរិមតៈ ជាមួយ សម្តេច សីហនុ វា មាន កំរិត ខុសគ្នា។ លោក លន់ នល់ ដើមឡើយ វា គ្រាន់តែ មាន ការបារម្ភ លើ សកម្មភាព នយោបាយ របស់ ស

[28] អសទិស : ដែលមិនដូចគ្នា, មិនត្រូវគ្នា, មិនប្រហែលគ្នា។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ម្ដេច សីហនុ ដែល លោក យល់ឃើញ ថា វា អាចនឹងនាំមក គ្រោះថ្នាក់ ដល់ ប្រជាជាតិ, តែ លោក មិនដែល មាន គោលបំណង ម្ដងណាឡើយ នឹងជំទាស់ ចេញមុខនោះឡើយ ព្រោះ គំនិតនេះ វា នៅក្នុង តំបន់ហាមឃាត់ នៅក្នុង ចិត្តលោក ជារាស្ត្រ។ រីឯ ទ្រង់ សិរិមតៈ វិញ ទ្រង់ ចាំតែ ឱកាសល្អ ហុចឱ្យ ដើម្បី ចេញមុខប្រឆាំងនឹង នយោបាយ អសារ[29] របស់សម្ដេច សីហនុ ដែល ទ្រង់ យល់ឃើញថា វា ចង្រៃ សំរាប់ អនាគតជាតិ។ ដូច្នេះ នៅក្នុង ព្រឹត្តិការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០, ទ្រង់ សិរិមតៈ មាន ការរៀបចំ ច្បាស់លាស់ នៅ ក្នុង ចិត្តគំនិត, រីឯ លោក លន់ នល់ វិញ លោក រត់តាម ព្រឹត្តិការណ៍ ព្រោះ លោក អវត្តមាន នៅក្នុង រយៈពេល សំខាន់ នៃ អធិករណ៍ (ពី ខែ វិច្ឆិការ ដល់ ពាក់កណ្ដាល ខែ កុមភៈ) រវាង រដ្ឋាភិបាល និង សម្ដេច សីហនុ ព្រោះ លោក នៅ ព្យាបាលរោគ នៅ ស្រុកបារាំង។ ទ្រង់ សិរិមតៈ មើលឃើញ ថា ថាស ជញ្ជីង របស់ រដ្ឋាភិបាល វា ធ្ងន់ជាង ថាស របស់ សម្ដេច សីហនុ ដូច្នេះ ទ្រង់ ចាប់យក ឱកាស នៃ ការបះបោរ នៃ ប្រជាកសិករ នៅ ខេត្ត ស្វាយរៀង និង អ្នកភ្នំពេញ ប្រឆាំងនឹង វត្តមាន កងទ័ព យៀកកុង នៅលើ ដែនដីខ្មែរ ដើម្បី រៃ ដែកគោល នៃ អធិករណ៍ ឱ្យកាន់តែចូលជ្រៅ ដូចយ៉ាង ការពាក់ព័ន្ធ ដោយប្រយោល ជាមួយ អ្នកចែកខិត្តប័ណ្ណ ប្រឆាំងនឹង សម្ដេច សីហនុ នៅក្នុង ហ្វូង នៃ បាតុករ

29 អសារៈ ឥតខ្លឹម, ឥតប្រយោជន៍, ឥតអំពើ។

នៅ ក្រុងភ្នំពេញ។ ជាការពិត ទង្វើនោះ នឹងអាចឱ្យ មាន គ្រោះថ្នាក់ណាស់ ដល់ខ្លួនទ្រង់ផ្ទាល់ ព្រោះ អ្នកចែក ខិត្តប័ណ្ណ ពីររូប[30] ត្រូវបាន ពួក បាតុករ ធ្វើប្រជាទណ្ឌ ស្ទើរ តែស្លាប់ខ្លួន កុំតែក្រុម គិញ ធ្វើ អន្តរាគម យកចេញ ពី ហ្វូងនោះទាន់ ហើយ នាំទៅ ទុក និង ព្យាបាល នៅ ក្រសួង សន្តិសុខជាតិ។ លោក វរសេនីយ ប៉ូ ហ៊ែល[31] ដែល ជា នាយកស្នងការដ្ឋាន នគរបាល រាជធានី ភ្នំពេញ ទាមទារ ឱ្យនាំ ជនទាំងពីរនោះ មក ស្នងការដ្ឋាន នគរបាល កណ្តាល ជា ប្រឆាប់ ព្រោះវា នៅក្នុង ដែន សមត្ថកិច្ច របស់គាត់, តែ នៅពេលនោះ នៅ ក្រសួង សន្តិសុខជាតិ គ្មាន នរណាម្នាក់ ហ៊ាន អារកាត់ រឿងនោះឡើយ។ ការទាមទាររបស់លោក ប៉ូ ហ៊ែល នោះ ដែល នាំឱ្យ ទ្រង់ សិរិមតៈ បញ្ជា ឱ្យចាប់ ឃុំ លោក ប៉ូ ហ៊ែល ក្នុង ឋានៈទ្រង់ ជា រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ព្រោះលោក ប៉ូ ហ៊ែល មាន បំណង ធ្វើ រដ្ឋប្រហារ ទំលាក់រដ្ឋាភិបាល[32]។ ព្រឹត្តិការណ៍ទាំងនោះ ដែល នាំឱ្យ លោក លន់ ន

---

[30] អ្នកទាំងពីររូបនោះ ជា គ្រូបង្រៀន។

[31] លោក វរសេនីយឯក ប៉ូ ហ៊ែល ជា សាច់ញាតិ នៃ ព្រះរាជវង្សានុវង្ស។

[32] លោក ប៉ូ ហ៊ែល បានទូរស័ព្ទ ទៅ លោក អ៊ុម មានូរិន ឱ្យជួយ ធ្វើអន្តរាគមន៍ ក្នុង ឋានៈលោក ជា រដ្ឋលេខាធិការ ក្រសួង ការពារ ក្នុងផ្ទៃប្រទេស ដោយ ទទូច ឱ្យលោក អ៊ុម មានូរិន ចេញ អាជ្ញា ដល់ កងពលតូច នៃ តម្រួតក្រុងភ្នំពេញ ដែល ជា កងពិសេស សំរាប់ ការពារសន្តិសុខផ្ទាល់ របស់ សម្តេច សីហនុ ឱ្យចេញចាប់ រដ្ឋមន្ត្រី មួយជំនួនដែល លោក យល់ឃើញ ថា កំពុង រៀបចំធ្វើ រដ្ឋប្រហារ ទំលាក់ សម្តេចសីហនុ ហើយ ឱ្យ កងតម្រួតខេត្ត (garde provinciale) គ្រប់ខេត្ត លាតទ័ព មកកាន់ រាជធានី ភ្នំពេញ ដើម្បី ទប់ កុំឱ្យមាន រដ្ឋប្រហារ។ ការហៅទូរស័ព្ទនោះ ត្រូវបាន ក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍ ថត សម្លេង

ល់ កោះប្រជុំ ជា បន្ទាន់ រដ្ឋមន្ត្រី បីរូប[33] និង ទីប្រឹក្សា ពិសេស របស់លោក នៅ គេហដ្ឋាន របស់លោក នៅ រាត្រី ថ្ងៃ ទី១៦ មីនា ថ្ងៃ ដែល មានកើតហេតុនោះ។ នៅពេលប្រជុំនោះ លោក លន់ នល់ ត្អូញត្អែ ថា ទង្វើ ដែល បានធ្វើ ដែល គ្មាន ការអនុញ្ញាត ពីលោក វា កាន់តែ ពង្រីក ទំនាស់ ជាមួយ សម្ដេច សីហនុ ដែល លោក នៅមាន សង្ឃឹម ថា នឹងមានច្រកចេញ ព្រោះ ព្រះមហាក្សត្រិយានី ធានា ថា នឹងអាច ទង់ទាញ បុត្រ របស់ព្រះអង្គ មករក ផ្លូវត្រឹមត្រូវ វិញបាន។ ចំពោះទ្រង់ សិរិមតៈ ទ្រង់គ្មាន ជំនឿនោះឡើយ ហើយ ប្រសិនបើ នៅ សម្ងំចាំ គឺ ច្បាស់ ជា ទុក ពេលវេលា ឱ្យសម្ដេច សីហនុ លាតទ័ព របស់ព្រះអង្គ វាយប្រហារ រដ្ឋាភិបាល ជា ពុំខាន។ ការបដិសេធ ទទួលជួប ប្រតិភូ ដែល មាតា របស់ព្រះអង្គ ចង់បញ្ជូន ឱ្យទៅរាយការណ៍ ថ្វាយដំណឹង អំពី ព្រឹត្តិការណ៍ ដែល កំពុង កើតឡើង នៅ ក្នុងស្រុក ជា សញ្ញា បង្ហាញ ថា សម្ដេច សីហនុ ជ្រើសរើស ផ្លូវ ទំនាស់ យកឈ្នះ ជា ដាច់ខាត ទោះបីព្រះអង្គ ត្រូវប្រើមធ្យោបាយបែបណាក៏ដោយ។ ដូច្នេះ ការរង់ចាំ គឺ ជា ការរង់ចាំ នៃ អសញ្ញាភាព[34] តែប៉ុណ្ណោះ

---

បាន ហើយ ក៏ប្រញាប់ យកទៅថ្វាយទ្រង់ សិរិមតៈ ដែល ជា ឧបនាយករដ្ឋមន្ត្រី គ្រប់គ្រង ក្រសួង។

[33] ទ្រង់ សិរិមតៈ ឧបនាយករដ្ឋមន្ត្រី ទី១ ទទួល បន្ទុក ក្រសួង មហាផ្ទៃ និង កិច្ចការសាសនា, លោក ឧប គឹម អាង ឧបនាយករដ្ឋមន្ត្រី ទី៣ ទទួល បន្ទុក ក្រសួង សេដ្ឋកិច្ចជាតិ និង ហិរញ្ញវត្ថុ, ឆន សុខុម រដ្ឋមន្ត្រី ក្រសួង សិក្សាធិការជាតិ និង យុវជន, អឹង ត្រាមុច ទីព្រឹក្សា ពិសេស របស់លោក លន់ នល់, លោក ជា អតីត រដ្ឋលេខាធិការ ក្រសួង សន្តិសុខជាតិ។

[34] អសញ្ញាភាព ៈ ដំណើរអស់ជីវិត។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ព្រោះ នរណា ក៏ដឹងដែរ ថា វិធី ចាត់ការ ផ្ដន្ទាទោស ដូច អសនី[35] ដល់ សត្រូវនយោបាយ របស់សម្ដេច សីហនុ វា មាន ភាព ឃោរឃៅ។ ដូច្នេះ សម្ដំ រង់ចាំសេចក្ដីស្លាប់ ដោយ អាច មាន មធ្យោបាយ សំរាប់ ការពារខ្លួន វា មិនមែន ជា មនុស្ស លោក នោះឡើយ។ មធ្យោបាយ សំរាប់ ការពារខ្លួន វា គ្មានអ្វី ក្រៅពី អំណាចរដ្ឋាភិបាល ពេញសិទ្ធិ នោះឯង។ ទទ្បីករណ៍[36] របស់ទ្រង់ សិរិមតៈ វា មិន កៀងគរ លោក លន់ នល់ បាន ងាយស្រួលនោះទេ ព្រោះលោក លន់ នល់ ជា រាស្ត្រ, មន្ត្រីរាជការ, អ្នករាជានិយម និង សីហនុនិយម, ដូច្នេះ ការប្រឆាំងនឹង សម្ដេច សីហនុ គឺ ជា អំពើ អសាធុ[37] ដាច់ខាត ព្រោះ សីហនុ ជា តំណាង នៃ គោលការណ៍ ដែល មាន នៅក្នុង ចិត្តគំនិត របស់ លោក។ ចិត្តគំនិតនោះ គឺ ប្រទេសសុខសោត បើមានទំនាស់ នឹង សម្ដេច ច្បាស់ ជា រដ្ឋរាស្ត្រច្របល់ កិច្ចការប្រយោជន៍ ហិន ហោច ឥតសល់ ព្រោះតែកង្វល់ ផ្ដល់ឱ្យតាមកាល។ ប៉ុន្តែ ទ្រង់ សិរិមតៈ មិនបាត់ ការអត់ធ្មត់ បន្ត ផ្ដល់ ទទ្បីករណ៍ ផ្សេងៗ ទៀត ដើម្បី បញ្ចុះបញ្ចូលលោក លន់ នល់ ដូចយ៉ាង ការលើក ឡើង អំពី ការបដិសេធ នៃ ប្រតិភូ នៃ យួនខាងជើង និង យៀកកុង មិនទទួលយក ឪសានវាទ របស់ រដ្ឋាភិបាលខ្មែរ ដែល កំណត់ កាលបរិច្ឆេទ ឱ្យពួកគេ ដកកងទ័ព ចេញ ពី ស្រុកខ្មែរ

---

35 អសនី : រន្ទះបាញ់។
36 ទទ្បីករណ៍ : សេចក្ដីសំអាង។
37 អសាធុ : ពុំប្រពៃ, មិនត្រឹមត្រូវ។

## លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ព្រោះ ពួកគេ ថា រឿងនេះ ជា កិច្ចការ របស់សម្ដេច សីហនុ មិន មែន ជា របស់ រដ្ឋាភិបាលខ្មែរ នោះឡើយ។ ហើយនឹង ការគាំទ្រ អាចមានបាន ពី សំណាក់ រដ្ឋសភា ដល់ រដ្ឋាភិបាល ក្នុង ទំនាស់ រវាង អំណាចនីតិប្រតិបត្តិ, អំណាចនីតិបញ្ញាតិ ជាមួយ ស្ថាប័ន ព្រះប្រមុខរដ្ឋ។ តែ ទន្ទ្រឹករណ៍ ទាំងឡាយនោះ វាហាក់ បីដូចជា មិនអាច ប្ដូរ មូល ចិត្តគំនិត រូបអារក្ស របស់លោក លន់ នល់ ជា អ្នករក្សា ដោយ យកចិត្តទុកដាក់ នៃ រាជានិយម និង សីហនុនិយម នោះឡើយ។ ដូច្នេះ ចិត្តអសទិស រវាង លោក លន់ នល់ នឹង ទ្រង់ សិរិមតៈ វា ជា ផ្លូវឆ្ងាយអន្លឹត ពីគ្នា ដែល អាចនាំឱ្យមាន ការឈ្លោះប្រកែក បែកបាក់គ្នា បាន។ តែ ចំណុចមួយ ដែល រក្សា អសម្ភិន្ទ[38] រវាង អ្នកទាំងពីរ គឺ ការថ្លឹង ទម្ងន់ របស់លោក លន់ នល់ រវាង សេចក្ដីប្ដេជ្ញាស្វាហាប់ របស់ ទ្រង់ សិរិមតៈ នឹង ចិត្តសាវ៉ា របស់សម្ដេច សីហនុ ដែល ប្រព្រឹត្ត មកលើលោកផ្ទាល់។ ចំពោះលោក អ្វី ដែល ទ្រង់ សិរិមតៈ កំពុង ធ្វើ គឺ ជា អំពើ គ្មានក្នុង គ្មានក្រៅ ជាមួយលោក, រីឯ សម្ដេច សីហនុ ព្រះអង្គ មាន ល្បិចកល រហូត អាច ទុក ជា ចិត្តក្រឡេច ក្រឡក ព្រោះ អ្វី ដែល ព្រះអង្គ សន្យាក្រឡៅ[39] ឱ្យលោកធ្វើ កិច្ច ការជាតិ បែរ ជា ព្រះអង្គ គេចកែពី ស ទៅ ខ្មៅ មិនសម ជា គ្រួ រួមចង្ក្រានជាតិ ជាមួយគ្នា។ ដូច្នេះ ការសម្រេចចិត្ត របស់លោក លន់ នល់ ឈប់ ធ្វើ សហការ ជាមួយ សម្ដេច សីហុន វា មាន ចិត្ត

---

[38] អសម្ភិន្ទ : មិនបែកបាក់គ្នា។

[39] ក្រឡៅ : ជាក់, ច្បាស់, ប្រាកដ, ស្លែង។

# លន់ នល់ - សិរិមតៈ : សត្រូវ ឬ មិត្ត ?

ស្មោះត្រង់ របស់ទ្រង់ សិរិមតៈ នៅក្នុង ដួងចិត្ត របស់លោក លន់ នល់។ ដូច្នេះ សូម មិត្ត អ្នកអាន យក ការយល់ឃើញ របស់យើងនេះ ទៅ ពិចារណា ថា តើ នៅក្នុង ព្រឹត្តការណ៍ ថ្ងៃ ទី១៨ មីនា ឆ្នាំ ១៩៧០ លោក លន់ នល់ និង ទ្រង់ សិរិមតៈ ជា សត្រូវ ឬ ជា មិត្ត នឹងគ្នា។ ដូច អ្នកខ្លះ យល់ឃើញ ថា អ្នកទាំងពីរ ជា សត្រូវ នឹងគ្នា ព្រោះ មាន កំណើត វណ្ណៈ ខុសគ្នា, តែ ក៏មាន អ្នកខ្លះទៀត យល់ឃើញ ខុស ថា អ្នកទាំងពីរ ជា មិត្ត នឹងគ្នា ព្រោះ ហ៊ាន ស្លាប់រស់រួម នៅក្នុង ការទំលាក់ សម្តេច សីហនុ ពីមុខដំណែង ដើម្បី ផលប្រយោជន៍ជាតិខ្មែរ តែមួយគត់។ ការណ៍នេះ វា ចារទុក ក្នុង ប្រវត្តិសាស្ត្រជាតិ, តែ ការវិនិច្ឆ័យ វា តែងតែ ប្រែប្រួល ទៅតាម បរិបទ នយោបាយ ក្នុង កាលមួយ និង ស្ថានភាព នយោបាយមួយ។ ម្យ៉ាងវិញ ថ្ងៃនេះ និង ថ្ងៃស្អែក វា ច្បាស់ជា មាន ចំណង តភ្ជាប់គ្នា តែ មិនច្បាស់ ជា មាន គំនិត តែមួយនោះឡើយ ព្រោះ ចិត្តគំនិត របស់ អ្នកចេះដឹង វា មាន ចលនា នៃ សេចក្តីចម្រើនឡើង ដែល ជា ពន្លឺ នៃ បញ្ញា សំរាប់ស្វែងរក សេចក្តីពិតមួយផ្សេងទៀត៕

**ចប់**